## សកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍

# សហភាពអឺរ៉ុបនៅក្នុងប្រទេសកម្ពុជា

ខែ ធ្នូ ២០០៦





# បុព្វកថា

នេះជារបាយការណ៍ទីបីស្តីពីសកម្មភាពសហប្រតិបត្តិការផ្នែកអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប EU នៅកម្ពុជា ដែលត្រូវបានហៅថា "សៀវភៅខៀវនៃសហភាពអឺរ៉ុប"។ គោលបំណងសៀវភៅខៀវនេះ គឺដើម្បីផ្តល់នូវទិដ្ឋភាពទូទៅមួយ ក៏ដូចជាសេចក្តីលំអិតជាក់លាក់អំពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់ EU (ដោយរាប់បញ្ចូលទាំងរដ្ឋជាសមាជិក និងគណៈកម្មការសហគមន៍អឺរ៉ុបផង) ដែលត្រូវបានផ្តល់ដល់ប្រទេសកម្ពុជា។ សៀវភៅនេះក៏ផ្តល់ផងដែរនូវព័ត៌មានទូទៅ និងថ្មីៗអំពីស្ថាប័ន និងគោលនយោបាយអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប។

ឆ្នាំ ២០០៥ ត្រូវបានកត់សំគាល់ថា ជាឆ្នាំដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍនៃរបៀបវារៈជាសកលរបស់ EU។ ដើម្បីសម្រេចបាននូវការប្រឈមនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ EU បានធ្វើការប្តេជ្ញាក្នុងការបង្កើតឱ្យមានកិច្ចផ្តួចផ្តើមថ្មីៗ ដើម្បីផ្តល់ជំនួយអោយបានកាន់តែច្រើនឡើង និងដោយមានភាពឆាប់រហ័សជាងមុន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ផងដែរ។

EU គឺជាម្ចាស់ជំនួយធំជាងគេលើពិភពលោក ដែលផ្តល់ជំនួយស្មើនឹងចំនួន ៥៥%នៃ ODA ទាំងអស់។ ដើម្បីធ្វើការងារឱ្យបានច្រើនជាងមុន រដ្ឋជាសមាជិករបស់ EU បានឯកភាពនៅក្នុងខែ ឧសភា ឆ្នាំ ២០០៥ ក្នុងការបង្កើន ODA របស់ខ្លួនឱ្យបានច្រើនដោយបានកំណត់ទិសដៅរយៈពេលមធ្យមថ្មីមួយ ដើម្បីផ្តល់ជំនួយនេះឱ្យបានដល់ ០,៥៦% នៃចំណូលជាតិសរុប (GNI) នៅក្នុងឆ្នាំ ២០១០ និងអោយដល់ ០,៧% នៃ GNI នៅក្នុងឆ្នាំ ២០១៥ ដែលជាទិសដៅចុងក្រោយ។ ជាការច្បាស់លាស់ណាស់ថា សេចក្តីសម្រេចរបស់ EU នេះ នឹងមានន័យថា ជាការបង្កើនជំនួយជាបន្ថែមចំនួន ២០ពាន់លានអឺរ៉ូ ប្រចាំឆ្នាំ អោយបាន នៅត្រឹមឆ្នាំ ២០១០។ យ៉ាងយូរនៅត្រឹមឆ្នាំ ២០១៥ ជំនួយរបស់ EU នឹងឈានដល់ ៩០ ពាន់លានអឺរ៉ូ ក្នុងមួយឆ្នាំៗ។

ទាក់ទងនឹងការគំរាមកំហែងជាសកលនៃរោគផ្តាសាយបក្សី EU បានដើរតួនាទីនាំមុខនៅក្នុងសន្និសីទអន្តរជាតិថ្នាក់រដ្ឋមន្ត្រីស្តីពីការផ្តល់ជំនួយ ដើម្បីទប់ស្កាត់ការរាតត្បាតនៃរោគផ្តាសាយបក្សី និងផ្តាសាយមនុស្ស ដែលត្រូវបានធ្វើឡើងនៅទីក្រុងប៉េកាំងនៅដើម ឆ្នាំ២០០៦។ រដ្ឋជាសមាជិករបស់ EU និងគណៈកម្មការសហគមន៍អឺរ៉ុប បានសន្យាផ្តល់ជំនួយរួមគ្នាប្រមាណ ២១៤ លានអឺរ៉ូ (២៦៧,៥លានដុល្លា)។ ក្នុងចំនួនទឹកប្រាក់នេះ គណៈកម្មការសហគមន៍អឺរ៉ុបនឹងផ្តល់ ៨០ លានអឺរ៉ូ (១០០លានដុល្លា) សម្រាប់ប្រទេសទីបី ក្នុងនោះ ៣០ លានអឺរ៉ូ (៣៧,៥លាន ដុល្លា) នឹងផ្តោតលើប្រទេសចំនួនបីនៅអាស៊ីអាគ្នេយ៍។

លើសពីនេះ ទាក់ទងនឹងជំនួយសម្រាប់ពាណិជ្ជកម្ម សន្និសីទនៃអង្គការពាណិជ្ជកម្មពិភពលោកដែលបានធ្វើឡើងនៅក្រុងហុងកុង បានអនុម័តកញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍមួយ ដែលនេះគឺជាសមិទ្ធិផលដែលទទួលបាន ដោយមានការជំរុញប្រកបដោយការតាំងចិត្តរបស់ EU ទៅលើប្រទេសជឿនលឿនដទៃទៀត។ EU ខ្លួនឯង បានប្រកាសអំពីការប្តេជ្ញាយ៉ាងច្រើនជាបន្ថែមទៀតក្នុងការផ្តល់ជំនួយទាក់ទងនឹងពាណិជ្ជកម្ម (TRA) ឱ្យដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយធ្វើការប្តេជ្ញាផ្តល់ជំនួយបន្ថែមចំនួន ១ ពាន់លានអឺរ៉ូ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១០ ដែលនេះមានន័យថា ជំនួយសរុបរបស់ EU ទាក់ទងនឹងពាណិជ្ជកម្មនឹងកើនឡើងដល់ ២ ពាន់លានអឺរ៉ូ ចាប់ពីឆ្នាំ ២០១០ ទៅ។

ទាក់ទងនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ EU ជាមួយប្រទេសកម្ពុជា ក្នុងនាមជាដៃគូអភិវឌ្ឍន៍ធំជាងគេរបស់ប្រទេសកម្ពុជា លើផ្នែកជំនួយឥតសំណង និងជាដៃគូពាណិជ្ជកម្មមួយក្នុងចំណោមដៃគូសំខាន់នានា សហភាពអឺរ៉ុប (រដ្ឋសមាជិកនៃ EU និងគណៈកម្មការសហគមន៍អឺរ៉ុប) បានផ្តល់វិភាគទានរួមគ្នាច្រើនជាង ១៣៧ លានអឺរ៉ូ ឬច្រើនជាង ១៧១ លានដុល្លា នៅក្នុងឆ្នាំ ២០០៦។ ជំនួយនេះ បានជួយអោយមានការរីកចម្រើនខាងការអភិវឌ្ឍជនបទ ការអប់រំសុខភាព ការអភិវឌ្ឍសេដ្ឋកិច្ច អភិបាលកិច្ច និងសិទ្ធិមនុស្ស ក៏ដូចជាខាងការបោសសំអាតមីនផងដែរ។ ទឹកប្រាក់សរុបដែលបានផ្តល់ដោយ EU តាមរយៈ ODA សម្រាប់ប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០៧ មានប្រមាណ ១៤៤ លានអឺរ៉ូ ឬត្រូវជា ១៨០ លានដុល្លាអាមេរិក។

ការរីកចម្រើនជាច្រើនបានធ្វើរួចមកហើយ ប៉ុន្តែនៅមានការងារជាច្រើនថែមទៀតដែលត្រូវសម្រេចឱ្យបាន។ EU នៅតែបន្តផ្តល់ការគាំទ្ររបស់ខ្លួនចំពោះកិច្ចប្រឹងប្រែងទាំងនេះនៅក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត។ ព័ត៌មាននៅក្នុង "សៀវភៅខៀវរបស់ EU" នេះបង្ហាញយ៉ាងច្បាស់អំពីការប្តេជ្ញាជាបន្តរបស់ EU ដើម្បីផ្តល់ការគាំទ្រចំពោះសកម្មភាពអភិវឌ្ឍន៍សម្រាប់ជាប្រយោជន៍របស់ប្រជាជនកម្ពុជា។

យើងជឿជាក់ថា កាបោះពុម្ពផ្សាយលើកទីបី ជាភាសាអង់គ្លេស បារាំង និងខ្មែរនេះ នឹងផ្តល់ជាប្រយោជន៍ដល់អ្នកអានជាច្រើន រួមទាំងអ្នកកសាងគោលនយោបាយ អ្នកឯកទេស និងអ្នកស្រាវជ្រាវ នៅក្នុងរដ្ឋាភិបាល និងស្ថាប័នផ្តល់ជំនួយនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងមូល។ ប្រតិភូគណៈកម្មការសហគមន៍អឺរ៉ុប ធ្វើការប្រឹងប្រែងគ្រប់លទ្ធភាព ដើម្បីធ្វើឱ្យ "សៀវភៅខៀវរបស់ EU" មានសុក្រឹត្យភាព និងផ្តល់ព័ត៌មានយ៉ាងច្រើន ហើយយើងក៏សូមស្វាគមន៍ផងដែរចំពោះរាល់យោបល់ និងទស្សនៈកែលំអប្រកបដោយការស្ថាបនាពីលោកអ្នក។



# កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ EU នៅកម្ពុជា

## សេចក្តីផ្តើម

សហភាពអឺរ៉ុប EU គឺជាដៃគូអភិវឌ្ឍន៍ធំជាងគេរបស់កម្ពុជា ក្នុងការផ្តល់ជំនួយឥតសំណង និងជាដៃគូពាណិជ្ជកម្មមួយក្នុងចំណោមដៃគូសំខាន់បំផុតរបស់កម្ពុជា។ ជំនួយពី EU ចេញពីប្រភពចំនួនពីរគឺ : កម្មវិធីនានារបស់ប្រទេសដែលជាសមាជិករបស់ EU និងកម្មវិធីដែលផ្តល់មូលនិធិដោយថវិការបស់ EU និងដែលគ្រប់គ្រងដោយគណៈកម្មការសហគមន៍អឺរ៉ុប ដែលជាទីភ្នាក់ងារប្រតិបត្តិរបស់ EU។ ម្ចាស់ជំនួយពី EU ដែលធ្វើការសកម្មបំផុតក្នុងប្រទេសកម្ពុជា រួមមាន ដាណឺម៉ាក់ បារាំង អាល្លឺម៉ង់ ស៊ុយអែដ ចក្រភពអង់គ្លេស និងគណៈកម្មការសហគមន៍អឺរ៉ុប។ កម្មវិធីរបស់ម្ចាស់ជំនួយពី EU មាននៅក្នុងផ្នែកអប់រំសុខាភិបាល ហ៊ីវ/អេដស៍ ការអភិវឌ្ឍន៍ជនបទ វិមជ្ឈការនិងសហវិមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឯកជន។

ប្រទេស **ដាណឺម៉ាក់** គាំទ្រលើការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទ តាមរយៈការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ។ ការគាំទ្រនេះ នឹងត្រូវផ្តល់ជូនដល់ថ្នាក់មូលដ្ឋាន អោយបានច្រើនជាលំដាប់។ ប្រទេសដាណឺម៉ាក់ ក៏ផ្តល់មូលនិធិដល់គម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលផងដែរលើផ្នែកសិទ្ធិមនុស្ស ការប្រឆាំងអំពើពុករលួយ និងសកម្មភាពនានា ដើម្បីអភិវឌ្ឍន៍យុទ្ធសាស្ត្រកែទម្រង់ច្បាប់ និងតុលាការ។

ប្រទេស **បារាំង** គឺជាម្ចាស់ជំនួយសម្រាប់គម្រោងហ៊ីវ/អេដស៍ និងបានផ្តល់ការគាំទ្រដល់ស្ថាប័នអប់រំជាន់ខ្ពស់ ព្រមទាំងបានចូលរួមនៅក្នុងការពង្រឹង និងកសាងកម្មវិធីក្នុងវិស័យច្បាប់ សុខភាព និងរដ្ឋបាល។ ប្រទេសនេះក៏ចូលរួមយ៉ាងសកម្មផងដែរនៅក្នុងផ្នែកអភិវឌ្ឍន៍ជនបទ និងកំណែទម្រង់វិស័យពាណិជ្ជកម្ម។ លើសពីនេះ ប្រទេសបារាំងផ្តល់មូលនិធិដល់គម្រោងរបស់ NGOs លើការងារសិទ្ធិមនុស្សផងដែរ។

ប្រទេស **អាល្លឺម៉ង់** ក៏ជាអ្នកផ្តល់ជំនួយសម្រាប់គម្រោងជាច្រើនផងដែរ។ នៅក្នុងផ្នែកអប់រំ ប្រទេសនេះផ្តល់ការគាំទ្រលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលផ្នែកប្រភេទសហគ្រាសខ្នាតតូច។ នៅក្នុងវិស័យសុខាភិបាល ប្រទេសអាល្លឺម៉ង់ផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់វិស័យសុខាភិបាល និងសុខភាពបន្តពូជ។ កំណែទម្រង់រដ្ឋបាល និងវិស័យពាណិជ្ជកម្មក៏ដូចជាការ អភិវឌ្ឍជនបទ គឺជាវិស័យផ្សេងទៀតដែលទទួលការយកចិត្តទុកដាក់ផងដែរ។

ប្រទេស **ស៊ុយអែដ** ផ្តល់ការគាំទ្រជាចំបងដល់ការពង្រីកកម្មវិធីអប់រំជាមូលដ្ឋានរបស់អង្គការយូនីសែហ្វ កម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាល និងគម្រោងរបស់ NGOs ខាងផ្នែកសិទ្ធិមនុស្ស។

កម្មវិធីអភិវឌ្ឍន៍របស់ចក្រភពអង់គ្លេសសម្រាប់ឆ្នាំ ២០០៥-០៨ ផ្តោតលើការងារជាមួយទីភ្នាក់ងារដទៃទៀត ដើម្បីពង្រឹងប្រសិទ្ធិភាពជំនួយ។ វិស័យនៃការយកចិត្តទុកដាក់ រួមមាន ការគាំទ្រដើម្បីកែលំអលទ្ធភាពប្រើប្រាស់សេវាសុខាភិបាល និងព័ត៌មានអំពីមេរោគអេដស៍ និងអំពីជម្ងឺអេដស៍ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អភិបាលកិច្ចមូលដ្ឋាន និងកែលំអការចិញ្ចឹមជីវិតនៅជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ។

សមាជិកផ្សេងទៀតនៃ EU រួមមាន **អូទ្រីស សាធារណរដ្ឋឆែក ហ្វាំងឡង់ អ៊ីតាលី ហុងគ្រី លុចហ្សំបួរ ហូឡង់ ប៉ូឡូញ និងអេស្ប៉ាញ** ផ្តល់ការគាំទ្រសម្រាប់ការបោសសំអាតមីន ការចុះបញ្ជីដីធ្លី ថាមពលជនបទ ការប្រើប្រាស់ទីផ្សារ សកម្មភាពរបស់ NGOs ជំនួយមនុស្សធម៌ កិច្ចសហប្រតិបត្តិការវប្បធម៌ អភិបាលកិច្ចល្អ និងសិទ្ធិមនុស្ស ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ ការអប់រំ និងការអភិវឌ្ឍធនធានមនុស្ស។

គណៈកម្មការសហគមន៍អឺរ៉ុប ផ្តល់ការគាំទ្រដល់ផ្នែកសន្តិសុខស្បៀង និងការអភិវឌ្ឍចម្រុះនៅជនបទ ការអប់រំ និងសុខភាពជាមូលដ្ឋាន បរិស្ថាន វិមជ្ឈការ ដំណើរការលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ក៏ដូចជា កម្មវិធីកំណែទម្រង់សេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់រដ្ឋាភិបាលផងដែរ។ សកម្មភាពថ្មីៗ កំពុងត្រូវបានរៀបចំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដែលផ្តោតលើ "ជនក្រីក្រ" តាមរយៈការលើកកំពស់សហគ្រាសខ្នាតតូច និងមធ្យម ក្នុងវិស័យកសិឧស្សាហកម្មនិងការបន្តគាំទ្រលើវិស័យពាណិជ្ជកម្ម ដើម្បីជម្រុញកំណើននៃការនាំចេញ។ កាគាំទ្រក៏នឹងផ្តល់ផងដែរ សម្រាប់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ឆ្នាំ ២០០៦ គឺជាឆ្នាំដ៏មានសារៈសំខាន់សម្រាប់ដៃគូនានារបស់ EU។ ពួកគេបានធ្វើការជាមួយគ្នាដើម្បីបង្កើតនូវផែនទីបង្ហាញផ្លូវមួយ (Roadmap) សម្រាប់បង្កើនប្រសិទ្ធិភាពជំនួយ ដែលនឹងកំណត់វិធានការជាច្រើន ដើម្បីបំពេញបន្ថែម និងគាំទ្រយន្តការសម្របសម្រួលដែលមានស្រាប់រវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។ ផែនទីបង្ហាញផ្លូវនេះ នឹងតម្រង់ទិសដៃគូនានារបស់ EU នៅក្នុងកិច្ចប្រឹងប្រែងដើម្បីរួមវិភាគទានចំពោះកំណើនប្រសិទ្ធិភាពនៃជំនួយពី EU ដល់ប្រទេសកម្ពុជា។



# ប្រទេសបែលហ្ស៊ិក

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ បែលហ្ស៊ិក - កម្ពុជា

ចាប់តាំងពីឆ្នាំ ២០០៥ មក ប្រទេសកម្ពុជាលែងក្លាយជាប្រទេសដៃគូរបស់បែលហ្ស៊ិក ខាងជំនួយអភិវឌ្ឍន៍ផ្លូវការទៀតហើយ។ ជាលទ្ធផល រដ្ឋាភិបាលប្រទេសបែលហ្ស៊ិក មិនបានផ្ដល់ការគាំទ្រដល់គម្រោងថ្មីឡើយ ប៉ុន្តែផ្ដោតការយកចិត្តទុកដាក់លើការអនុវត្តគម្រោងដែលមានស្រាប់ ដែលប្រទេសនេះបានផ្ដល់ការគាំទ្រ និងការពិនិត្យលទ្ធភាពបន្តគម្រោងទាំងនោះ។

គោលបំណងចំបងនៃជំនួយ ODA ពីប្រទេសបែលហ្ស៊ិកចំពោះកម្ពុជា គឺការបង្កើតឱ្យមានការអភិវឌ្ឍធនធានមនុស្សដោយនិរន្តរភាពនៅកម្ពុជា។ ជាពិសេស គោលនយោបាយអភិវឌ្ឍន៍នៃប្រទេសបែលហ្ស៊ិកក្នុងប្រទេសកម្ពុជា មានគោលដៅអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ការយកចិត្តទុកដាក់ពិសេសត្រូវបានផ្ដោតលើកិច្ចប្រឹងប្រែងរបស់ជាតិ ដើម្បីជម្រុញអភិបាលកិច្ចល្អ ដែលផ្ដោតលើវិស័យគន្លឹះជាអាទិភាពរបស់រដ្ឋាភិបាល (ពោលគឺ ការអប់រំសុខភាព ការអភិវឌ្ឍដោយចីរភាព និងការប្រើប្រាស់ធនធានធម្មជាតិសម្រាប់នាវាចរនៅក្នុងទន្លេមេគង្គ) នៅក្នុងតំបន់ភូមិសាស្ត្រដែលមានជំនួយតិចជាងគេ ដែលផ្ដោតលើក្រុមមនុស្សទន់ខ្សោយ និងងាយរងគ្រោះបំផុត។

**ជំនួយODA ដែលផ្ដល់ដោយប្រទេសបែលហ្ស៊ិកដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)**

| វិស័យ | មូលនិធិផ្ដល់ជាក់ស្ដែង ឆ្នាំ ២០០៥ | គ្រោងផ្ដល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្ដល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ការអប់រំ | ២.៨៨០.០៩៣ អឺរ៉ូ | ៤.០៩៩.០០០ អឺរ៉ូ | ២.៥០២.៦០០ អឺរ៉ូ |
| សុខាភិបាល | ២.៩០៥.១០៣ អឺរ៉ូ | ២.០០០.០០០ អឺរ៉ូ | ២.៥០០.០០០ អឺរ៉ូ |
| ការផ្គត់ផ្គង់ទឹកនិងអនាម័យ | | | |
| រដ្ឋាភិបាលនិងសង្គមស៊ីវិល | ៣៨៧.៥៧០ អឺរ៉ូ | ១៩៤.៧០០ អឺរ៉ូ | |
| សេវាសង្គមផ្សេងទៀត | ២១៨.៨៧៣ អឺរ៉ូ | | |
| ការដឹកជញ្ជូន និងការស្តុកទុក | ១.៣៤០.១០៣ អឺរ៉ូ | ៤៥៩.០០០ អឺរ៉ូ | |
| កសិកម្ម ព្រៃឈើ និងការនេសាទ | ១១៩.៩២៤ អឺរ៉ូ | | |
| កិច្ចការពារបរិស្ថាន | ១២១.៦៣១ អឺរ៉ូ | | |
| ស្ត្រីក្នុងការអភិវឌ្ឍ | ៧៦១.៦០០ អឺរ៉ូ | | |
| ការអភិវឌ្ឍទីក្រុងនិងជនបទ | ៤៦០.២១៩ អឺរ៉ូ | | |
| ជំនួយកម្មវិធី | | | |
| ការគាំទ្រដល់ NGOs | ៣០៥.៨៣៧ អឺរ៉ូ | ពុំទាន់មានទិន្នន័យ* | ពុំទាន់មានទិន្នន័យ* |
| **សរុប** | **៩.៥០០.៩៥៣ អឺរ៉ូ** | **៦.៧១២.៧០០ អឺរ៉ូ** | **៥.០០២.៦០០ អឺរ៉ូ** |

** រំពឹងថាប្រហាក់ប្រហែលនឹងឆ្នាំ ២០០៥ ដែរ*

# សាធារណរដ្ឋឆែក



## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆែក - កម្ពុជា

នៅទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៨០ កម្ពុជាស្ថិតក្នុងចំណោមដៃគូនៅអាស៊ីដ៏សំខាន់មួយរបស់អតីតឆេកូស្លូវ៉ាគី។ ជំនួយចំបងៗសម្រាប់ការអភិវឌ្ឍច្រើនតែផ្តល់តាមរយៈការផ្គត់ផ្គង់បរិក្ខារ ដូចជា បរិក្ខារសម្រាប់ការដឹកជញ្ជូន គ្រឿងយន្តសម្រាប់ការសាងសង់ គ្រឿងយន្តសម្រាប់វាយនភ័ណ្ឌ និងសម្រាប់ផលិតស្បែកជើង រោងចក្រផលិតស្ករស ម៉ាស៊ីនភ្លើងម៉ាហ្សូត បរិក្ខារវិស្វកម្មថាមពលវារីអគ្គិសនីនិងថាមពលកំដៅ និងបរិក្ខារសម្រាប់ផលិតសំបង់កង់។ ការសាងសង់ស្ថានីយ៍ថាមពលកំដៅនៅចាក់អង្រែនៃទីក្រុងភ្នំពេញ គឺជាគម្រោងធំជាងគេ ដែលផ្តល់ហិរញ្ញប្បទានដោយឆេកូស្លូវ៉ាគី។ លើសពីនេះ អ្នកជំនាញការពេទ្យពីឆេកូស្លូវ៉ាគីត្រូវបានបញ្ជូនមកធ្វើការនៅក្នុងមន្ទីរពេទ្យមួយចំនួននៅកម្ពុជាផងដែរ។

ជំនួយអភិវឌ្ឍន៍ចំបងៗផ្សេងទៀតពីអតីតឆេកូស្លូវ៉ាគី គឺកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលសម្រាប់និស្សិតពីប្រទេសតតិយលោក។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ១៩៧០ និង ១៩៨០ និស្សិតជាច្រើនពីកម្ពុជាបានទៅសិក្សានៅក្នុងវិទ្យាល័យ និងសកលវិទ្យាល័យនៃរដ្ឋឆែក។ កម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាល នៅតែបន្តដោយជោគជ័យរហូតដល់សព្វថ្ងៃនេះ (អាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គាំទ្រជនបរទេសឱ្យសិក្សានៅគ្រឹះស្ថានអប់រំជាន់ខ្ពស់សាធារណៈនៅសាធារណរដ្ឋឆែក ផ្អែកតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលជាប់ជាកាតព្វកិច្ចសម្រាប់សាធារណរដ្ឋឆែក ឬនៅក្នុងកម្មវិធីជំនួយបរទេសរបស់សាធារណរដ្ឋឆែក)។ បច្ចុប្បន្ន មាននិស្សិតកម្ពុជាចំនួនប្រាំរូបកំពុងសិក្សានៅក្នុងសាធារណរដ្ឋឆែក។

នៅឆ្នាំ ២០០៦ សាធារណរដ្ឋឆែកបានរួមវិភាគទានចំនួន ៣០.០០០ ដុល្លាស.រ.អា ចំពោះការសាងសង់សាលាបឋមសិក្សាមួយកន្លែងនៅវត្តគិរីស្រះស្រង់។ បន្ថែមពីលើ ODA អង្គការមួយចំនួនពីរដ្ឋឆែក (ADRA សាធារណរដ្ឋឆែក Stonoka-Centipede) បានផ្តល់ជំនួយដល់កម្ពុជា (ជាពិសេសចំពោះគម្រោងទាក់ទងនឹងមេរោគអេដស៍/ជម្ងឺអេដស៍)។

វីរៈជនដ៏ឧត្តុង្គឧត្តមរបស់សង្គមកម្ពុជាជាច្រើន ដូចជា សម្តេចព្រះនរោត្តម សីហមុនី (ដែលបានសិក្សានៅទីក្រុងប្រាក រវាងឆ្នាំ១៩៦២-១៩៧៥) អាចនិយាយភាសាឆែក និងបានថែរក្សាទំនាក់ទំនងជាមួយសាធារណរដ្ឋឆែកផងដែរ។ ប្រការនេះផ្តល់ជាមូលដ្ឋានយ៉ាងប្រសើរសម្រាប់កិច្ចសហប្រតិបត្តិការខាងវប្បធម៌។ សាធារណរដ្ឋឆែកមានបំណងពង្រីងវិស័យវប្បធម៌នៃកិច្ចសហប្រតិបត្តិការឆែក-កម្ពុជា។ ដើម្បីរំលឹកខួបឆ្នាំលើកទី ៥០ នៃទំនាក់ទំនងការទូតរវាងសាធារណរដ្ឋឆែក និងកម្ពុជា នៅក្នុងឆ្នាំ២០០៦ សម្តេចព្រះនរោត្តមសីហមុនី បានធ្វើទស្សនកិច្ចនៅសាធារណរដ្ឋឆែក ហើយស្ថានទូតក៏បានចាត់ចែងការបង្ហាញសិល្បៈមួយចំនួនផងដែរ។

**ជំនួយ ODA ដែលផ្តល់ដោយសាធារណរដ្ឋឆែក ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)**

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ជំនួយមនុស្សធម៌នៅខេត្តតាកែវ | ១៣០.០០០ អឺរ៉ូ | ១៨០.០០០ អឺរ៉ូ | ១០០.០០០ អឺរ៉ូ |
| ការវិភាគនៃរចនាសម្ព័ន្ធសំណង់អង្គរ | | ៨.០០០ អឺរ៉ូ | ៥០.០០០ អឺរ៉ូ |
| **សរុប** | ១៣០.០០០ អឺរ៉ូ | ១៨៨.០០០ អឺរ៉ូ | ១៥០.០០០ អឺរ៉ូ |



# ប្រទេសដាណឺម៉ាក់

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដាណឺម៉ាក់ - កម្ពុជា

គោលបំណងចំបងនៃការិយាល័យផ្នែកសហប្រតិបត្តិការអភិវឌ្ឍន៍ដាណឺម៉ាក់ (DANIDA) នៅក្នុងគោលនយោបាយអភិវឌ្ឍន៍របស់ខ្លួន គឺកាត់បន្ថយភាពក្រីក្រ ដែលទាក់ទងជាមួយបញ្ហាអន្តរវិស័យ ដូចជា អភិបាលកិច្ចល្អ ការប្រឆាំងអំពើពុករលួយ សិទ្ធិមនុស្ស សមភាពយេនឌ័រ និងបរិស្ថាន ។

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដាណឺម៉ាក់ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីជំនួយដល់វិស័យធនធានធម្មជាតិ និងបរិស្ថាន ។ កិច្ចព្រមព្រៀងសហប្រតិបត្តិការរយៈពេលប្រាំឆ្នាំ លើកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) ត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ ២០០១ ក្នុងក្របខ័ណ្ឌនៃការសន្យាផ្តល់ជំនួយ ២៤០ លាន ក្រោនដាណឺម៉ាក់ (ច្រើនជាង ៣២ លាន អឺរ៉ូ) ។ កម្មវិធី NRE ត្រូវបានគ្រោងដើម្បីបញ្ចប់នៅឆ្នាំ ២០០៦ ។

កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលទាំងពីរ ស្តីពីការអនុវត្តកម្មវិធីរួមគ្នាថ្មីមួយរបស់ DANIDA/DFID ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត (NRML) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៦ ។ កម្មវិធីថ្មីនេះ នឹងត្រូវអនុវត្តចាប់ពីពាក់កណ្តាលឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ ដែលមានគោលបំណងអភិវឌ្ឍន៍រួម ដូចតទៅ ៖

ដើម្បីដោះស្រាយការកាត់បន្ថយភាពក្រីក្រនៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម និងរួមចំណែកកែលំអការចិញ្ចឹមជីវិតរបស់ជនក្រីក្រនៅជនបទ និងការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានធម្មជាតិ តាមរយៈការគ្រប់គ្រងធនធានធម្មជាតិ និងការចាត់ចែងអភិបាលកិច្ចបានល្អប្រសើរ ។

**កម្មវិធីថ្មីនេះ មានសមាសភាគចំបងចំនួនបីគឺ ៖**

- ការគ្រប់គ្រងធនធានធម្មជាតិ ក្នុងក្របខ័ណ្ឌវិមជ្ឈការ និងសហវិមជ្ឈការ
- សង្គមស៊ីវិល និងទីផ្សារ "ដែលគាំទ្រជនក្រីក្រ"
- ការអភិវឌ្ឍវិស័យ និងគោលនយោបាយ ។

កម្មវិធីនេះនឹងគ្របដណ្តប់ខេត្ត-ក្រុងចំនួន ១៤ ក្នុងចំណោម ២៤ ខេត្ត-ក្រុងក្នុងប្រទេសកម្ពុជា ដែលភាគច្រើនស្ថិតនៅក្រៅតំបន់ផលិតស្រូវចំបងក្នុងប្រទេស និងឃុំចំនួន ៧០៧ ឬត្រូវជាប្រមាណ ៤០% នៃចំនួនឃុំទាំងអស់នៅកម្ពុជា ។ ការសន្យារបស់ DANIDA/DFID ចំពោះកម្មវិធីនេះ មានដល់ ៣៦០ លានក្រោន ដាណឺម៉ាក់ ។

DANIDA ក៏អនុវត្តកម្មវិធីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យផងដែរ ដែលផ្តល់ការគាំទ្រដល់ NGOs និងគ្រឹះស្ថានរបស់រដ្ឋាភិបាល ។ កម្មវិធីនេះទ្រទ្រង់សកម្មភាពនានា ដែលគាំទ្រសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ ប្រយុទ្ធប្រឆាំងអំពើពុករលួយ និងបង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុងរដ្ឋបាលសាធារណៈលើសពីនេះ NGOs មួយចំនួនពីប្រទេសដាណឺម៉ាក់ កំពុងអនុវត្តគម្រោងនានា ដែលទទួលមូលនិធិពី DANIDA នៅក្នុងប្រទេសកម្ពុជា លើវិស័យសុខាភិបាល កំណែទម្រង់ច្បាប់ និងតុលាការ និងការអភិវឌ្ឍកសិកម្មផងដែរ ។



### ជំនួយ ODA ដែលផ្តល់ដោយប្រទេសដាណឺម៉ាក់ ដល់កម្ពុជា (ឆ្នាំ ២០០៥_០៧)

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---:|---:|---:|
| កម្មវិធី NRE | ២៧.៣៩៩.៩២២ | ៥៦.៨៨៦.១៦០ | ៧៥.៣៩៦.០០០ |
| ការគាំទ្រដល់ NGOs | ៣០.០០០.០០០ | ២៥.២០០.០០០ | ៣២.៣០០.០០០ |
| **សរុប គិតជាក្រោនដាណឺម៉ាក់** | **៥៧.៣៩៩.៩២២** | **៨២.០៨៦.១៦០** | **១០៧.៦៩៦.០០០** |
| **សរុប គិតជា អឺរ៉ូ (€)** | **៧.៧១៥.០៤៣ អឺរ៉ូ** | **១១.០៣៣.០៨៦ អឺរ៉ូ** | **១៤.៤៧៥.២៦៧ អឺរ៉ូ** |



# ប្រទេសបារាំង

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ បារាំង - កម្ពុជា

ក្រៅពីវិភាគទានក្របខ័ណ្ឌពហុភាគី កិច្ចសហប្រតិបត្តិការបារាំង បានអនុវត្តនៅក្នុងប្រទេសកម្ពុជា លើវិស័យទូទៅមួយចំនួននៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍ (DGCID) របស់ក្រសួងការបរទេស និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)។ ស្ថាប័នទាំងពីរនេះបានធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមគោលការណ៍ដែលមានចែងនៅក្នុងឯកសារក្របខ័ណ្ឌសហប្រតិបត្តិការ ឆ្នាំ ២០០៦-២០១០។

ការគាំទ្រនីតិរដ្ឋ និងអភិបាលកិច្ចល្អ ត្រូវបានអនុវត្តជាផ្នែកមួយនៃការពង្រឹងក្របខ័ណ្ឌតុលាការ និងមន្ត្រីរដ្ឋបាលជាពិសេស ចៅក្រម ក្រឡាបញ្ជី មេធាវី មន្ត្រីនគរបាល និងមន្ត្រីស៊ីវិល តាមរយៈការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់អនុវត្តគោលការណ៍ច្បាប់ឆ្ពោះទៅដំណើរការកសាងច្បាប់ បទប្បញ្ញត្ត ការផ្សព្វផ្សាយច្បាប់ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការបង្កើតទម្រង់កិច្ចការពាណិជ្ជកម្ម។

**ការផ្តោតលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលអនុញ្ញាតឱ្យមានការយកចិត្តទុកដាក់លើវិស័យអាទិភាពចំនួនបីគឺ :**

- កសិកម្ម និងសន្តិសុខស្បៀង ដែលមានគោលបំណងទ្រទ្រង់តម្រូវការអាហារូបត្ថម្ភ រួមចំណែកចំពោះការអភិវឌ្ឍកសិកម្មចម្រុះ ដោយផ្តោតការយកចិត្តទុកដាក់លើបញ្ហាទឹក សន្តិសុខដីធ្លី និងការបង្កើតអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងពង្រឹងកាលានុវត្តភាពនានាសម្រាប់ការនាំចេញ ជាពិសេសលើវិស័យដំណាំកៅស៊ូ។
- កិច្ចការពារបរិស្ថាន និងជីវៈចម្រុះ ជាពិសេសធនធានទឹកក្នុងអាងទន្លេមេគង្គ និងព្រៃក្នុងតំបន់ជួរភ្នំក្រវ៉ាញ។
- សុខភាព និងការប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ គាំទ្រដោយវិធានសកលនៃប្រព័ន្ធសុខាភិបាលរបស់កម្ពុជា ដើម្បីកែលំអការផ្តល់សេវាព្យាបាល លទ្ធភាពទទួលសេវា និងហិរញ្ញប្បទាន។

**អន្តរាគមន៍អន្តរវិស័យ ដែលជម្រុញឱ្យមានការលើកកំពស់ :**

- ការអប់រំជាន់ខ្ពស់ និងការស្រាវជ្រាវ ដើម្បីបណ្តុះបណ្តាលឡើងវិញនូវអ្នកជំនាញឯកទេសក្នុងវិស័យចំបងៗមួយចំនួនខាងផ្នែក ពេទ្យ សេដ្ឋកិច្ច តុលាការ និងវិស្វករ។
- លើកកំពស់ការផ្លាស់ប្តូរវប្បធម៌ និងក្រុមប្រទេសអ្នកប្រើភាសាបារាំង ដោយបានអនុវត្តសកម្មភាពដើម្បីថែរក្សាបេតិកភណ្ឌ បណ្តុះបណ្តាលភាសាបារាំង និងផ្សព្វផ្សាយវប្បធម៌បរទេស។
- ស្តារសង្គមស៊ីវិលឡើងវិញ ដោយគាំទ្រដោយផ្ទាល់ដល់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

ប្រទេសបារាំងបានផ្តល់ការគាំទ្រដូចគ្នានេះដែរ តាមរយៈការផ្តល់អ្នកជំនាញការសម្រាប់វិស័យគន្លឹះ ដើម្បីជួយកសាងគោលនយោបាយទីក្រុងទេសចរណ៍ និងទឹកស្អាត។

| | |
|---|---|
| មូលនិធិផ្តល់សម្រាប់ឆ្នាំ ២០០៥ | ១៧ លាន អឺរ៉ូ |
| មូលនិធិផ្តល់សម្រាប់ឆ្នាំ ២០០៦ (ប៉ាន់ស្មាន) | ២១,៨ លានអឺរ៉ូ |

*ប្រភព*

| | ២០០៥ | ២០០៦ |
|---|---|---|
| លានដុល្លា ស.រ.អា | ២១ | ២៦ |
| អត្រាប្តូរប្រាក់អឺរ៉ូ | ១.២៤៤១ | ១.១៩៣៤ |



# ប្រទេសហ្វាំងឡង់

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហ្វាំងឡង់ - កម្ពុជា

ហ្វាំងឡង់ បានគាំទ្រប្រទេសកម្ពុជាចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០មក ។ កិច្ចសហប្រតិបត្តិការនេះច្រើនតែផ្តោតលើជំនួយមនុស្សធម៌ ដែលសង្កត់ធ្ងន់លើការស្តាបនាឡើងវិញ និងផ្តល់មូលនិធិតាមរយៈ UNDP ។ នៅក្នុងអំឡុងពេលដប់ឆ្នាំកន្លងមកនេះ ប្រទេសហ្វាំងឡង់ក៏បានផ្តល់ការគាំទ្រដំណើរការបោសសំអាតមីននៅកម្ពុជាផងដែរតាមរយៈ NGOs និង INGOs ។

នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ប្រទេសហ្វាំងឡង់ បានចូលរួមនៅក្នុងគម្រោងសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគី ។ គម្រោងទាំងនេះផ្សំឡើងដោយគម្រោងចុះបញ្ជីដីធ្លី និងគម្រោងមួយសម្រាប់ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ។ លើសពីនេះ ប្រទេសហ្វាំងឡង់ បានផ្តល់ការគាំទ្រដល់ប្រទេសកម្ពុជា តាមរយៈគម្រោងមេគង្គថ្នាក់តំបន់ ដូចជាការធ្វើម៉ូដែលជលសាស្ត្រ ដោយសហការជាមួយគណៈកម្មការទន្លេមេគង្គ និងធនាគារអភិវឌ្ឍន៍អាស៊ី ។ តាមរយៈមូលនិធិសម្រាប់កិច្ចសហប្រតិបត្តិការនៅមូលដ្ឋាន ប្រទេសហ្វាំងឡង់ បានគាំទ្រគម្រោងដែលអនុវត្តដោយ NGOs កម្ពុជា ។

ប្រតិបត្តិការមនុស្សធម៌បោសសំអាតមីនក៏ដូចជា គម្រោងរបស់ NGO និង INGO បានជួយជនរងគ្រោះ ធ្វើសមាហរណកម្មឡើងវិញទៅក្នុងសង្គម ផ្សព្វផ្សាយការអប់រំអំពីមីន និងការបោសសំអាតមីន ។

គម្រោងទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ បានពង្រឹងសមត្ថភាពរបស់អាជ្ញាធរជាតិ និងមូលដ្ឋាន ដើម្បីទប់ស្កាត់ការជួញដូរ ។ គម្រោងនេះក៏បានជួយជនរងគ្រោះដោយសារការជួញដូរ ដើម្បីធ្វើសមាហរណកម្មទៅក្នុងសង្គមឡើងវិញផងដែរ ។

គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី បានកែលំអសន្តិសុខលើកម្មសិទ្ធិដី និងលើកកំពស់ការអភិវឌ្ឍទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធិភាព ។ គម្រោងនេះបានជួយកសាងគោលនយោបាយជាតិ ក្របខ័ណ្ឌបទប្បញ្ញត្តិ ស្ថាប័នសម្រាប់រដ្ឋបាលដីធ្លី និងការចេញ និងចុះបញ្ជីកម្មសិទ្ធិដី ។ លើសពីនេះគម្រោងនេះបាននាំឱ្យមានការបង្កើតប្រព័ន្ធរដ្ឋបាលដីធ្លីប្រកបដោយប្រសិទ្ធិភាព និងតម្លាភាពផងដែរ ។

គោលដៅនៃកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់មេគង្គ គឺអភិវឌ្ឍន៍តំបន់ជនបទក្នុងប្រទេសកម្ពុជា គាំទ្រ SMEs និងចាត់ចែងរដ្ឋបាលសាធារណៈ ។ ជាក់ស្តែង គោលបំណងនៃគម្រោងគាំទ្រការចិញ្ចឹមជីវិតដោយនិរន្តរភាពនៅក្នុងតំបន់បឹងទន្លេសាប គឺការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយផ្តោតលើវិស័យឯកជន សុខភាព បរិស្ថាន និងព្រៃឈើ ។

**ជំនួយ ODA ដែលផ្តល់ដោយប្រទេសហ្វាំងឡង់ ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)**

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ប្រតិបត្តិការមនុស្សធម៌ដើម្បីកំចាត់មីន | ១.០២០.០០០ អឺរ៉ូ | ១.០២០.០០០ អឺរ៉ូ | ៩២០.០០០ អឺរ៉ូ |
| ទប់ស្កាត់ការជួញដូរ | ៣០០.០០០ អឺរ៉ូ | ៣០០.០០០ អឺរ៉ូ | ៥០០.០០០ អឺរ៉ូ |
| ការចុះបញ្ជីដីធ្លី | ៤៧០.១៦២ អឺរ៉ូ | ៨៣២.៤៩២ អឺរ៉ូ | ៨៥០.០០០ អឺរ៉ូ |
| មូលនិធិសម្រាប់សហប្រតិបត្តិការមូលដ្ឋាន | | ៧៥.៨៩៥ អឺរ៉ូ | |
| ផ្សេងៗទៀត (NGOs) | ៤៤១.៨៣០ អឺរ៉ូ | ២២៩.០០២ អឺរ៉ូ | |
| **សរុប** | **២.២៣១.៩៩២ អឺរ៉ូ** | **២.៤៥៧.៣៨៩ អឺរ៉ូ** | **២.២៧០.០០០ អឺរ៉ូ** |

# ប្រទេសអាល្លឺម៉ង់



## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ អាល្លឺម៉ង់ - កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសគោលសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់អាល្លឺម៉ង់។ វិស័យគន្លឹះនៃកិច្ចសហប្រតិបត្តិការគឺ :

- សុខាភិបាល
- ការអភិវឌ្ឍជនបទ និង
- លើកកំពស់អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ និងសង្គមស៊ីវិល។

នៅក្នុងក្របខ័ណ្ឌនៃវិស័យខាងក្រោយនេះ ប្រទេសអាល្លឺម៉ង់ផ្តល់មូលនិធិសម្រាប់គម្រោងវិមជ្ឈការសិទ្ធិស្ត្រី និងការកសាងសមត្ថភាពក្នុងគ្រឹះស្ថានសាធារណៈ ដើម្បីគាំទ្រក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់ការអភិវឌ្ឍតាមបែបចូលរួម និងដំណើរការប្រជាធិបតេយ្យ។ ការអភិវឌ្ឍជនបទ ផ្សំឡើងដោយសកម្មភាពនានា ដើម្បីបង្កើនផលិតភាព និងភាពសំបូរបែបនៃផលិតផល គាំទ្រសហគ្រាសខ្នាតតូច និងជំនួយដើម្បីកែទម្រង់ការគ្រប់គ្រងដីធ្លី និងសិទ្ធិលើការប្រើប្រាស់ដី ក៏ដូចជាការពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទផងដែរ។ កិច្ចសហប្រតិបត្តិការខាងវិស័យសុខាភិបាលផ្តោតលើសុខភាពបន្តពូជ ការថែទាំសុខភាពមាតា និងកុមារ ការធានាគុណភាព និងការធានារ៉ាប់រងសុខភាពសង្គមក្នុងប្រទេសកម្ពុជា។

លើសពីនេះ ប្រទេសអាល្លឺម៉ង់បានផ្តល់ជំនួយឥតសំណងចំនួន ២,៣ លានអឺរ៉ូ សម្រាប់បំពេញការចំណាយសម្រាប់សាលាក្តីខ្មែរក្រហម និងចូលរួមផងដែរនៅក្នុងការអភិរក្ស និងស្តារឡើងវិញនូវប្រាសាទអង្គរវត្ត និងព្រះគោ ក៏ដូចជាក្នុងជំនួយមនុស្សធម៌សម្រាប់ការបោសសំអាតមីនផងដែរ។

មកទល់ពេលនេះ ប្រទេសអាល្លឺម៉ង់បានសន្យាផ្តល់ជំនួយជិត ១៨២ លានអឺរ៉ូ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី។ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ប្រទេសអាល្លឺម៉ង់បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ និងផ្តោតសកម្មភាពសម្រាប់ទីជនបទ។

ជំនួយអភិវឌ្ឍន៍ភាគច្រើន ត្រូវបានអនុវត្តដោយទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ), KfW Entwicklungsbank និងទីភ្នាក់ងារសេវាអភិវឌ្ឍន៍នៃប្រទេសអាល្លឺម៉ង់ (DED)។

### ជំនួយ ODA ដែលផ្តល់ដោយប្រទេសអាល្លឺម៉ង់ ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| សុខាភិបាល | ៤.២៤៦.០០០ អឺរ៉ូ | ២.៥៩០.៥០០ អឺរ៉ូ | |
| ការអភិវឌ្ឍជនបទ | ៧.៥៥៩.៨០៦ អឺរ៉ូ | ៨.៤៣៥.៥០០ អឺរ៉ូ | |
| អភិបាលកិច្ច | ៣.៤៧៨.០០០ អឺរ៉ូ | ៥.០២៩.០០០ អឺរ៉ូ | |
| NGOs និងផ្សេងទៀត | ៤.៥១៧.០០០ អឺរ៉ូ | ៤.៥៤០.០០០ អឺរ៉ូ | |
| សរុប | ១៩.៨០០.៨០៦ អឺរ៉ូ | ២០.៥៩៥.០០០ អឺរ៉ូ | ២១.០០០.០០០ អឺរ៉ូ |



# ប្រទេសហុងគ្រី

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហុងគ្រី - កម្ពុជា

ឆ្នាំ ២០០៦ កត់សំគាល់ខួបឆ្នាំលើកទី ៥០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសហុងគ្រី និងកម្ពុជា។ មកដល់ឆ្នាំ ១៩៩០ ផ្នែកចំបងនៃទំនាក់ទំនងនេះគឺ ជំនួយឯកត្តោភាគីរបស់ប្រទេសហុងគ្រី ដល់ប្រទេសកម្ពុជា ទន្ទឹមនឹងការផ្លាស់ប្តូរជាប្រចាំនូវប្រតិភូអ្នកនយោបាយជាន់ខ្ពស់។ នៅចុងបញ្ចប់នៃសង្រ្គាមស៊ីវិល មន្ត្រីប៉ូលីស និងមន្ត្រីរដ្ឋបាលហុងគ្រីចំនួន ១៣០ នាក់បានចូលរួមនៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

នៅក្នុងអំឡុងទស្សនកិច្ចរបស់ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងខែមករា ឆ្នាំ ២០០៥ នៅទីក្រុងប៊ុយដាប៉ែស ភាគីទាំងពីរបានធ្វើការអះអាងឡើងវិញអំពីឆន្ទៈរបស់ខ្លួនដើម្បីបន្តកិច្ចសហប្រតិបត្តិការទ្វេភាគី។ កាលានុវត្តភាពអំណោយផលដែលបានកត់សំគាល់ គឺក្នុងវិស័យសេដ្ឋកិច្ច ក៏ដូចជាកិច្ចសហប្រតិបត្តិការលើការអប់រំ និងការអភិវឌ្ឍផងដែរ។ មណ្ឌលកុមារកំព្រានៅកំពង់កន្ទួត ឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏សំខាន់របស់យើង ដោយសារត្រូវបានកសាងឡើងតាមរយៈកិច្ចសហប្រតិបត្តិការសង្គមរបស់ប្រទេសហុងគ្រី កាលពី ២២ ឆ្នាំមុន។

ដោយសារឧបសគ្គខាងថវិកា កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ហុងគ្រីនៅក្នុងប្រទេសកម្ពុជាបានផ្តោតលើគម្រោងមួយចំនួនតូចក្នុងនោះគម្រោងដែលសំខាន់គឺមណ្ឌលកុមារកំព្រាកម្ពុជា-បារាំង-ហុងគ្រី។ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មូលនិធិ ODA របស់ប្រទេសហុងគ្រី ត្រូវបានផ្តល់តាមរយៈស្ថានទូត ឬ NGOs ហុងគ្រី និងអង្គការសប្បុរសនានា សម្រាប់ការស្តារឡើងវិញនូវអាគារនានា ក៏ដូចជាការកែលំអបរិក្ខារ និងលក្ខខណ្ឌនៃការរស់នៅរបស់កុមារនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័ន។ លើសពីនេះ ឱសថ និងបរិក្ខារពេទ្យក៏ត្រូវបានផ្តល់ដល់មន្ទីរពេទ្យកុមារនៅទីក្រុងភ្នំពេញផងដែរ។

ប្រទេសហុងគ្រីមានការប្តេជ្ញាដើម្បីកំណត់វិស័យផ្សេងទៀត ដែលប្រទេសនេះអាចផ្តល់ជំនួយបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជា៖ វិស័យទាំងនោះអាចរួមបញ្ចូល កិច្ចការពារធនធានទឹកសាប ការទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិ សុខាភិបាល ការអប់រំ និងកសិកម្ម។ លើសពីនេះ ស្ថានទូតធ្វើការយ៉ាងសកម្មដើម្បីគ្រោង និងធ្វើការអនុវត្តគម្រោងទ្វេភាគីជាមួយដៃគូ EU និងម្ចាស់ជំនួយនានាផ្សេងទៀតដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា។

**ការចំណាយមូលនិធិODA ហុងគ្រីក្នុងប្រទេសកម្ពុជាគឺ ឆ្នាំ ២០០៥: ៥០.០០០ អឺរ៉ូ និងឆ្នាំ ២០០៦: ៤៧.២០០ អឺរ៉ូ។**

# ប្រទេសអ៊ីតាលី



## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ អ៊ីតាលី - កម្ពុជា

សកម្មភាពសហប្រតិបត្តិការអ៊ីតាលីនៅកម្ពុជា បានផ្តោតលើការផ្តល់ជំនួយដល់ប្រជាពលរដ្ឋកម្ពុជា និងស្ថាប័ននានារបស់កម្ពុជា លើវិស័យខ្លះៗដែលពាក់ព័ន្ធជាងគេ និងដែលមានឥទ្ធិពលទៅលើការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ សកម្មភាពនានា ដែលបានអនុវត្ត បានផ្តោតជាចំបងលើវិស័យចំបងចំនួនពីរគឺ : ការកសាងសមត្ថភាពស្ថាប័ន ដោយផ្តោតការយកចិត្តទុកដាក់ ដោយឡែកលើការប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចខាងផ្លូវភេទលើកុមារ និងការអភិវឌ្ឍសេដ្ឋកិច្ច។

យុទ្ធសាស្ត្រផ្តល់ជំនួយសម្រាប់ឆ្នាំខាងមុខ ផ្អែកលើគម្រោងដែលបានប្រកាសរួចមកហើយ ដែលបានបង្ហាញលទ្ធផលយ៉ាងល្អ ទាំងលើការលើកកំពស់ការគោរពសិទ្ធិមនុស្ស និងក្នុងការជួយ និងកែលំអការអភិវឌ្ឍសេដ្ឋកិច្ច។

ជាក់ស្តែង រដ្ឋាភិបាលអ៊ីតាលីបានផ្តល់មូលនិធិសម្រាប់គម្រោងចំនួនពីរ។ គម្រោងមួយត្រូវបានអនុវត្តដោយ IOM នៅក្នុងខេត្តចំនួនប្រាំ តាមបណ្តោយព្រំដែននៃប្រទេសកម្ពុជា។ គម្រោងផ្សេងទៀតត្រូវបានអនុវត្តនៅថ្នាក់តំបន់ ដោយអង្គការយូនីសេហ្វ និងមានគោលដៅកែលំអក្របខ័ណ្ឌច្បាប់ និងសន្តិសុខ ហើយជាលទ្ធផល នឹងលើកកំពស់ការគោរពសិទ្ធិមនុស្សរបស់ជនរងគ្រោះដោយសារការជួញដូរ និងការកេងប្រវ័ញ្ចខាងផ្លូវភេទ។ គម្រោងទាំងនេះពង្រឹងកិច្ចប្រឹងប្រែងដែលបានធ្វើឡើងដោយរដ្ឋាភិបាលអ៊ីតាលី ដើម្បីកែលំអលក្ខខណ្ឌរស់នៅរបស់ជនដែលងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ។

ដើម្បីឆ្លើយតបនឹងបញ្ហានៃការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់ថ្នាំញៀន និងនៅក្នុងពន្ធនាគារ រដ្ឋាភិបាលអ៊ីតាលី បានចូលរួមក្នុងគម្រោង UNDOC ដែលមានគោលដៅកែលំអកិច្ចសហប្រតិបត្តិការ រវាងវិស័យសន្តិសុខសាធារណៈ និងកម្មវិធីដែលផ្អែកលើសហគមន៍ សម្រាប់កាត់បន្ថយភាពងាយរងគ្រោះដោយសារមេរោគអេដស៍ បណ្តាលពីការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធធនាគារ។

រដ្ឋាភិបាលអ៊ីតាលីបានត្រៀមរួចមកហើយនូវទឹកប្រាក់ចំនួន ៣.៧១៣.៩៧៩ អឺរ៉ូ សម្រាប់គម្រោងស្រោចស្រពនៅជនបទក្នុងខេត្តបាត់ដំបង ដែលគាំទ្រដោយអង្គការ FAO ដែលគួរតែនឹងត្រូវអនុវត្តនៅក្នុងពេលឆាប់ៗខាងមុខនេះ និងសម្រាប់រយៈពេលបីឆ្នាំ។

មូលនិធិពីប្រទេសអ៊ីតាលីត្រូវបានផ្តល់ជាសំខាន់តាមរយៈទីភ្នាក់ងារពហុភាគី ប៉ុន្តែគម្រោងខ្លះត្រូវអនុវត្តតាមរយៈ NGOs។



## ជំនួយ ODA ដែលផ្តល់ដោយប្រទេសអ៊ីតាលី ដល់កម្ពុជា (ឆ្នាំ ២០០៥_០៧)

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| **ការអប់រំ**<br>• Progetto Continenti<br>• ការពង្រឹងកិច្ចផ្តួចផ្តើមជំនួញនៅថ្នាក់ក្រោមបំផុត | ១៤៥.៣៣៣ អឺរ៉ូ | ១០៥,០០ ដុល្លា ស.រ.អា | |
| **រដ្ឋាភិបាល និងសង្គមស៊ីវិល**<br>• IOM<br>• UNODC | ២៥០.០០០ ដុល្លាស.រ.អា* | ២៧១.១០៤ អឺរ៉ូ | ២៧១.១០៤ អឺរ៉ូ |
| **សេវាសង្គមស៊ីវិលផ្សេងទៀត**<br>• យូនីសេហ្វ | ៤៩៧.៦៣៤ អឺរ៉ូ | ៤៩៧.៦៣៤ អឺរ៉ូ | ៤៧៥.៦៣៤ អឺរ៉ូ ** |
| **ការអភិវឌ្ឍទីក្រុង និងជនបទ**<br>• FAO | | | ៣.២៦៨.៣០២ ដុល្លាស.រ.អា **** |

** កម្មវិធីប្រចាំតំបន់ មូលនិធិផ្តល់ឱ្យគ្រប់ប្រទេសទាំងអស់ដែលមានចំណាប់អារម្មណ៍ ។*

*** កម្មវិធីប្រចាំតំបន់ មូលនិធិផ្តល់ឱ្យគ្រប់ប្រទេសទាំងអស់ដែលមានចំណាប់អារម្មណ៍ ។*

**** គម្រោងនេះគួរតែចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ ២០០៧ និងបន្តសម្រាប់រយៈពេល ៣ឆ្នាំ ។*

# ប្រទេសហូឡង់



## កិច្ចសហប្រតិបត្តិការលើការងារអភិវឌ្ឍន៍របស់ប្រទេសហូឡង់ជាមួយកម្ពុជា

### សេចក្តីពិពណ៌នា/ទិសដៅ

ចាប់តាំងពីឆ្នាំ ១៩៩៨-២០០៤ ប្រទេសហូឡង់ បានផ្តល់ជំនួយខាងអភិវឌ្ឍន៍ដល់កម្ពុជា ដែលគិតជាទឹកប្រាក់ប្រមាណជា ២-២.៥ លានអឺរ៉ូ ក្នុងមួយឆ្នាំៗ។ កិច្ចសហប្រតិបត្តិការខាងផ្នែកការអភិវឌ្ឍរបស់ប្រទេសហូឡង់ ត្រូវបានធ្វើឡើងភាគច្រើនតាមរយៈអង្គការពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលនានា។ ឆ្នាំ ២០០៤ គឺជាឆ្នាំមួយ ដែលត្រូវបានកត់សំគាល់ឃើញថា មានការកែប្រែលើគោលនយោបាយសហប្រតិបត្តិការខាងផ្នែកអភិវឌ្ឍន៍របស់ប្រទេស ហូឡង់ ដែលតំរូវអោយមានការកាត់បន្ថយនូវចំនួនប្រទេសដែលជាដៃគូ ដោយធ្វើការផ្តោតការយកចិត្តទុកដាក់ទៅលើប្រទេសនៅទ្វីបអាហ្វ្រិកវិញ។ ជាលទ្ធផល ជំនួយខាងផ្នែកអភិវឌ្ឍន៍ផ្លូវការរវាងថ្នាក់រដ្ឋាភិបាល និងរដ្ឋាភិបាលទាំងអស់មិនត្រូវបានបន្តទៀតឡើយនៅកម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ ជំនួយឧបត្ថម្ភរបស់ប្រទេសហូឡង់ នឹងត្រូវផ្តល់ជាបន្តទៅអោយអង្គជំនុំជំរះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា (ECCC) និងតាមរយៈកម្មវិធីគំរោងខ្នាតតូច (PKP)។ កម្មវិធីនេះ ជួយឧបត្ថម្ភគាំទ្រដល់ការអនុវត្តន៍ការផ្តួចផ្តើមដែលមានទ្រង់ទ្រាយតូច ដោយផ្អែកទៅលើការកាត់បន្ថយភាពក្រីក្រឈរលើសិទ្ធិជាមូលដ្ឋាន និងដែលមានរយៈពេលយ៉ាងច្រើនត្រឹម ១ ឆ្នាំ។ ថវិកាសរុបសំរាប់កម្មវិធីនេះ គឺមានចំនួន ១០០.០០០ អឺរ៉ូ ក្នុងឆ្នាំ ២០០៧។ (សំរាប់ពត៌មានពិស្តារ សូមមើលគេហទំព័រនេះ : www.mfa.nl/ban) ។

### សកម្មភាព និងទិន្នន័យសំខាន់ៗ

រហូតដល់ឆ្នាំ ២០០៤ ជំនួយខាងផ្នែកអភិវឌ្ឍន៍របស់ប្រទេសហូឡង់ ត្រូវបានផ្តោតជាសំខាន់លើអភិបាលកិច្ចល្អ និងវិស័យសិទ្ធិមនុស្ស។ យុទ្ធសាស្ត្រដកថយ ត្រូវបានអនុវត្តន៍ឡើងក្នុងឆ្នាំ ២០០៤ និង ២០០៥។ នៅឆ្នាំ ២០០៦ នេះ ជំនួយឧបត្ថម្ភរបស់ប្រទេសហូឡង់ ត្រូវបានផ្តល់ជូនជាសំខាន់ទៅអោយអង្គជំនុំជំរះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា។

| ផ្នែក | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|
| អភិបាលកិច្ចល្អ និងសិទ្ធិមនុស្ស | ៨៥៣.៦០០ | ៥៧០.០០០ | ៥០០.០០០ | ៥០០.០០០ |
| ការកាត់បន្ថយភាពក្រីក្រដោយឈរលើសិទ្ធិជាមូលដ្ឋាន | ៥០.០០០ | ៣០.០០០ | ១០០.០០០ | ១០០.០០០ |
| សរុប | ៩២២.៦០០ អឺរ៉ូ | ៦០០.០០០ អឺរ៉ូ | ៦០០.០០០ អឺរ៉ូ | ៦០០.០០០ អឺរ៉ូ |



# ប្រទេសប៉ូឡូញ

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ប៉ូឡូញ - កម្ពុជា

ប្រទេសប៉ូឡូញ និងកម្ពុជាបានបង្កើតទំនាក់ទំនងការទូតនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៥៦។ ចាប់តាំងពីពេលនោះមក ទំនាក់ទំនងមិត្តភាពទៅវិញទៅមករវាងប្រទេសទាំងពីរនេះត្រូវបានពង្រឹង និងអភិវឌ្ឍដោយជោគជ័យ។ ជំនួយ និងកិច្ចសហប្រតិបត្តិការរបស់ប្រទេសប៉ូឡូញ ជាមួយកម្ពុជា ផ្ដោតលើធនធានមនុស្ស វប្បធម៌ ការអប់រំ និងការអភិវឌ្ឍជនបទ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ និស្សិតមួយចំនួនពីកម្ពុជាបានបញ្ចប់ការសិក្សាពីសកលវិទ្យាល័យនៃប្រទេសប៉ូឡូញ តាមរយៈអាហារូបករណ៍ ដែលផ្ដល់ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប៉ូឡូញ។ ពីឆ្នាំ ១៩៨៩-១៩៩៣ បេសកកម្មប៉ូឡូញនៃអ្នកស្ដារបុរាណវត្ថុឡើងវិញ បានចូលរួមយ៉ាងសកម្មក្នុងការស្ដារឡើងវិញ និងអភិរក្សប្រាសាទអង្គរវត្ត និងផ្ទាំងគំនូរនៅតាមជញ្ជាំងព្រះវិហារព្រះកែវមរកតក្នុងក្រុងភ្នំពេញ។

សាធារណរដ្ឋប៉ូឡូញនឹងបន្តសកម្មភាពរបស់ខ្លួនដើម្បីជួយសង្គ្រោះអាគារប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដោយធ្វើការបម្លែងបំណុលរបស់ប្រទេសកម្ពុជាចំពោះប្រទេសប៉ូឡូញ សម្រាប់បំរើអោយគោលដៅនេះ។

ចាប់ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៦ ប្រទេសប៉ូឡូញបានផ្ដល់មូលនិធិសម្រាប់កសាងសំណង់អាគារសាលារៀនថ្មីចំនួនបួននៅក្នុងសាលារៀនជ័យមង្គល ស្រុកកៀនស្វាយ ខេត្តកណ្ដាល ជាមួយនឹងការផ្ដល់អគ្គិសនី ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធអនាម័យផងដែរ។ សាលារៀនត្រូវបានឱ្យឈ្មោះថា សាលាបឋមសិក្សាមិត្តភាពកម្ពុជា-ប៉ូឡូញ ជ័យមង្គល។

ក្នុងឆ្នាំ ២០០៧ ប៉ូឡូញនឹងធ្វើការប្រកាសគម្រោងសាងសង់សាលារៀនថ្មីមួយនៅសាលាបឋមសិក្សា ប្រសាម ស្រុកបាធាយ ខេត្តកំពង់ចាម។

### ជំនួយ ODA ដែលផ្ដល់ដោយប្រទេសប៉ូឡូញ ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)

| វិស័យ | មូលនិធិផ្ដល់ជាក់ស្ដែង ឆ្នាំ ២០០៥ | គ្រោងផ្ដល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្ដល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ការអប់រំ | ១៤.៥០០ អឺរ៉ូ | ២៣.០០០ អឺរ៉ូ | ២៥.០០០ អឺរ៉ូ |
| ការអភិវឌ្ឍជនបទ | | ១៦.៥០០ អឺរ៉ូ | ១៦.៥០០ អឺរ៉ូ |
| **សរុប** | **១៤.៥០០ អឺរ៉ូ** | **៣៩.៥០០ អឺរ៉ូ** | **៤១.៥០០ អឺរ៉ូ** |

# ប្រទេសអេស្ប៉ាញ



## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ អេស្ប៉ាញ - កម្ពុជា

ព្រះរាជាណាចក្រកម្ពុជាកំពុងទទួលបាននូវជំនួយអភិវឌ្ឍន៍កាន់តែច្រើនឡើងពីប្រទេសអេស្ប៉ាញ។ ផែនការសហប្រតិបត្តិការអភិវឌ្ឍន៍ដំបូងមួយឆ្នាំ ២០០៦-២០០៨ កំពុងត្រូវបានកសាងឡើង ដោយផ្តោតលើជំនួយទៅអនាគត និងសកម្មភាពរបស់ NGOs ។ ទន្ទឹមនឹងបទពិសោធន៍ជោគជ័យពីអតីតកាល វិស័យសង្គមជាអាទិភាព មានការទាក់ទងនឹងបញ្ហាយេនឌ័រ (ជាពិសេសការប្រឆាំងអំពើជួញដូរមនុស្ស) និងក្រុមងាយរងគ្រោះ (ធ្វើការជាមួយក្រុមជនពិការ)។ នៅក្រោមផែនការថ្មីនេះ កិច្ចសហប្រតិបត្តិការនេះនឹងត្រូវពង្រីកដល់វិស័យសេដ្ឋកិច្ច ក៏ដូចជាជនបទ ដូចជា អេកូទេសចរណ៍ និងវារីវប្បកម្ម។ វិស័យដែលបានអនុវត្តរួចមកហើយ គឺបច្ចេកវិទ្យាថ្មី (កិច្ចផ្តួចផ្តើមកម្មវិធីកំព្យូទ័រជាភាសាខ្មែរ) និងជំនួយមនុស្សធម៌ (ការដោះមីន)។ លើសពីនេះ សមាសភាគសំខាន់មួយនៃកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ គឺការបណ្តុះបណ្តាលជាន់ខ្ពស់សម្រាប់មន្ត្រី និងអ្នកឯកទេសក្នុងវិស័យនានា ដូចជា ជលផល សុខាភិបាល ទេសចរណ៍ និងថាមពលកកើតឡើងវិញ។

ដើម្បីពង្រឹងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា ប្រទេសអេស្ប៉ាញរំពឹងថា នឹងបង្កើតនូវវត្តមានជាអចិន្ត្រៃយ៍មួយនៅក្នុងឆ្នាំ ២០០៧។ ការធ្វើបែបនេះនឹងជួយគ្រប់គ្រងធនធានដែលនឹងកើនឡើង និងកែលំអគុណភាពនៃសកម្មភាព។ ការបន្សុី និងសម្របសម្រួលជំនួយ គឺជាអាទិភាពចំបង ដូច្នេះការចរចាររបស់អេស្ប៉ាញជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ដទៃទៀតនៅក្នុងការអភិវឌ្ឍប្រចាំថ្ងៃ នឹងកាន់តែកែលំអ។

### ជំនួយ ODA ដែលផ្តល់ដោយប្រទេសអេស្ប៉ាញ ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)

| វិស័យ | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ | គ្រោងផ្តល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្តល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ស្ត្រី និងការអភិវឌ្ឍ | ៤១០.១៨៦ អឺរ៉ូ | ៤៣០.៧៥០ អឺរ៉ូ | |
| ការអប់រំ | | ៥៩.៣២៥ អឺរ៉ូ | |
| ការអភិវឌ្ឍជនបទ | | ២១៤.៩២៥ អឺរ៉ូ | |
| ជំនួយមនុស្សធម៌ (ការដោះមីន) | | ៣០០.០០០ អឺរ៉ូ | |
| បច្ចេកវិទ្យាថ្មី | | ២០៨.០០០ អឺរ៉ូ | |
| មីក្រូហិរញ្ញវត្ថុ | | ១.៣៨០.០០០ អឺរ៉ូ | |
| សរុប | ៤១០.១៨៦ អឺរ៉ូ | ២.៥៩៣.០០០ អឺរ៉ូ | ៤.០០០.០០០ អឺរ៉ូ |



# ប្រទេសស៊ុយអែដ

## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ស៊ុយអែដ - កម្ពុជា

កិច្ចសហប្រតិបត្តិការប្រទេសស៊ុយអែដ ជាមួយកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ ១៩៧៩ ជាមួយជំនួយមនុស្សធម៌ ដែលផ្តល់តាមរយៈអង្គការសហប្រជាជាតិ។ កិច្ចសហប្រតិបត្តិការទ្វេភាគីដោយផ្ទាល់សម្រាប់រយៈពេលវែងរវាងប្រទេសទាំងពីរនេះ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៦។

គោលដៅរួមនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែដនៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេសសម្រាប់ឆ្នាំ ២០០២-២០០៦ គឺផ្តល់ការគាំទ្រដល់កិច្ចប្រឹងប្រែងប្រឆាំងភាពក្រីក្ររបស់ប្រទេសកម្ពុជា ស្របតាមគោលបំណងអភិវឌ្ឍន៍អន្តរជាតិ (គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍)។ គោលបំណងជាក់លាក់ចំនួនពីរនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ស៊ុយអែដគឺៈ

១- លើកកំពស់កាលានុវត្តភាពសម្រាប់បុរស ស្ត្រី និងកុមារក្រីក្រកម្ពុជានៅទីជនបទ ដើម្បីមានឥទ្ធិពលទៅលើ និងកែលំអលក្ខខណ្ឌនៃការរស់នៅរបស់ខ្លួន ។

២- លើកកំពស់លក្ខខណ្ឌដែលអំណោយផលសម្រាប់អភិបាលកិច្ចល្អ ដោយផ្តោតជាសំខាន់លើការអភិវឌ្ឍប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

នៅក្នុងគោលបំណងជាក់លាក់ដែលកត់សំគាល់ខាងលើ វិស័យចំនួនបីនៃកិច្ចសហប្រតិបត្តិការត្រូវបានកំណត់: ការកាត់បន្ថយភាពក្រីក្រនៅជនបទ ការអប់រំថ្នាក់បឋមសិក្សា និងការលើកកំពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ វិស័យទាំងអស់នេះតំណាងឱ្យការពង្រីកកិច្ចសហប្រតិបត្តិការដែលបានបង្កើតរួចមកហើយ និងត្រូវបានវិនិច្ឆ័យ ដើម្បីឱ្យមានទំនាក់ទំនងច្បាស់លាស់ដោយផ្ទាល់ និងដោយប្រយោលទៅលើការកាត់បន្ថយភាពក្រីក្រ។ ការយកចិត្តទុកដាក់ពិសេសនឹងផ្តោតលើការអភិវឌ្ឍនៅមូលដ្ឋាន និងអភិបាលកិច្ចនៅមូលដ្ឋាន តាមរយៈការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។ សមភាព យេនឌ័រ បរិស្ថាន ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងមេរោគអេដស៍/ជម្ងឺអេដស៍ នឹងបន្ថែមបញ្ចូលទៅក្នុងវិស័យចំបងៗទាំងនេះ តាមតែអាចធ្វើទៅបាន។

កិច្ចសហប្រតិបត្តិការ និងការផ្តល់ហិរញ្ញប្បទានរួមគ្នា ជាមួយសហប្រជាជាតិ អង្គការពហុភាគីដទៃទៀត និងដៃគូទ្វេភាគីនានានឹងនៅតែជាគោលការណ៍ដែលត្រូវប្រើប្រាស់សម្រាប់កិច្ចសហប្រតិបត្តិការរបស់ប្រទេសស៊ុយអែដ។ ជំនួយក៏នឹងបន្តផ្តល់ផងដែរតាមរយៈ NGOs។ ជារួម ជំនួយ ៤១៦ លានក្រោនស៊ុយអែដ (ប្រមាណ ៤៥លានអឺរ៉ូ) ត្រូវបានផ្តល់សម្រាប់អំឡុងឆ្នាំ ២០០២-២០០៥។ មកទល់ពេលនេះ ភាគច្រើននៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែដ បានផ្តល់ផលវិជ្ជមាន។

យុទ្ធសាស្ត្រថ្មីប្រចាំប្រទេស(២០០៧-២០១១) កំពុងត្រូវបានរៀបចំឡើង ដើម្បីសុំការអនុម័តឯកភាពនៅចុងឆ្នាំនេះដោយផ្តោតកាន់តែខ្លាំងទៅលើវិស័យសហប្រតិបត្តិការអភិវឌ្ឍន៍ ជាងយុទ្ធសាស្ត្រដែលមានស្រាប់។ យុទ្ធសាស្ត្រនេះផ្តោតលើការរួមចំណែកប្រមាណ ១៨០លាន ក្រោនស៊ុយអែដ (ប្រមាណ ១៩លាន អឺរ៉ូ) ក្នុងមួយឆ្នាំ ចំពោះសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា។

## ជំនួយ ODA ដែលផ្ដល់ដោយប្រទេសស៊ុយអែដ ដល់កម្ពុជា (ឆ្នាំ ២០០៥-០៧)

| វិស័យ | មូលនិធិផ្ដល់ជាក់ស្ដែង ឆ្នាំ ២០០៥ | គ្រោងផ្ដល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្ដល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| អភិបាលកិច្ចបែបប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស | ២.២២១.៥៩៨ អឺរ៉ូ | ៤.៣០៤.២០៧ អឺរ៉ូ | ៧.៦២៣.០៥៩ អឺរ៉ូ |
| វិស័យសង្គម | ៣.១៨៧.៩០៥ អឺរ៉ូ | ៥.១៤៣.៤៧៤ អឺរ៉ូ | ៦.២២៣ ៣០១ អឺរ៉ូ |
| ការគ្រប់គ្រងធនធានធម្មជាតិ | ៤.៦៤៣.៦២៩ អឺរ៉ូ | ៥.១៧៧.៩៩៤ អឺរ៉ូ | ៤៧៤.៦៤៩ អឺរ៉ូ |
| ជំនួយមនុស្សធម៌ រួមទាំងការបោសសំអាតមីន | ៤១០.៣៦៧ អឺរ៉ូ | | |
| កំណែទម្រង់សេដ្ឋកិច្ច | | | ៣.៧៩៧.១៩៥ អឺរ៉ូ |
| ផ្សេងទៀត | ៣៩៣.៥៦៤ អឺរ៉ូ | ៥៣១.០៦៨ អឺរ៉ូ | ១.២៩៩.២៨៥ អឺរ៉ូ |
| **សរុប** | **១០.៨១៧.០៦៣ អឺរ៉ូ** | **១៥.១៥៦.៧៤២ អឺរ៉ូ** | **១៩.៤១៧.៤៩០ អឺរ៉ូ** |




# ចក្រភពអង់គ្លេស

## នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID)

ផែនការផ្តល់ជំនួយប្រចាំប្រទេស (CAP) សម្រាប់រយៈពេលបីឆ្នាំរបស់ DFID សម្រាប់ឆ្នាំ ២០០៥/០៦-២០០៧/០៨ ត្រូវបានកសាងឡើងតាមរយៈដំណើរការរួមគ្នាមួយ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងអង្គការសហប្រជាជាតិដោយផ្អែកលើការវិភាគរួមគ្នា និងកម្មវិធីបំពេញគ្នា។ ផែនការ CAP កំណត់អំពីវិធីដែល DFID នឹងរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា និងការគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការយកចិត្តទុកដាក់ គឺផ្តោតលើការធ្វើការជាមួយរដ្ឋាភិបាល និងម្ចាស់ជំនួយនានា ដើម្បីសម្រេចឱ្យបាននូវឥទ្ធិពលជាអតិបរមាពីធនធានអភិវឌ្ឍន៍ រួមទាំងកែលំអអភិបាលកិច្ច និងដោះស្រាយបញ្ហានៃអំពើពុករលួយ ស្របនឹងឯកសារសថ្មីរបស់ DFID "លុបបំបាត់ភាពក្រីក្រលើពិភពលោក" : ធ្វើឱ្យអភិបាលកិច្ចជួយដល់អ្នកក្រ"។ DFID គឺជាយន្តការនាំមុខគេ ដើម្បីបង្កើនប្រសិទ្ធិភាពនៃជំនួយ និងការគាំទ្ររដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាពសុខដុម្មនីយកម្ម និងបន្សុីរបស់ខ្លួន។

**គោលបំណងរបស់ DFID នៅក្នុង CAP មានដូចតទៅ :**

១) រួមចំណែកដើម្បីបង្កើនយ៉ាងឆាប់រហ័សនូវឥទ្ធិពលនៃធនធានអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាដោយ :
ក. គាំទ្រកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព ។
ខ. តម្លាភាពកាន់តែរឹងមាំរបស់រដ្ឋាភិបាលចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន។
គ. ប្រកាន់យកទម្លាប់ល្អនៃការផ្តល់ជំនួយដល់ប្រទេសកម្ពុជា។

២) រដ្ឋាភិបាលនៅមូលដ្ឋានដែលមានការឆ្លើយតប មានគណនេយ្យភាព និងប្រសិទ្ធិភាពសម្រាប់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងអ្នកដែលសង្គមផាត់ចោល ។

៣) គាំទ្ររដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីពង្រឹងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្រីក្រ ។

៤) បង្កើនលទ្ធភាពដើម្បីទទួលសេវាសុខាភិបាល និងព័ត៌មានទាក់ទងនឹងសុខភាព។

DFID នឹងបន្តដោះស្រាយបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ តាមរយៈគោលបំណងទាំងអស់របស់ខ្លួននិងតាមរយៈការបន្តគាំទ្រដែលផ្តោតលើការដោះស្រាយបញ្ហារាតត្បាតនៃជម្ងឺនេះ។ ក្នុងគ្រប់ករណីទាំងអស់ ការគាំទ្រនឹងផ្តោតលើផលប្រយោជន៍សម្រាប់ជនក្រីក្រ និងអ្នកដែលសង្គមផាត់ចោល។

### ជំនួយ ODA ដែលផ្តល់ដោយចក្រភពអង់គ្លេស ដល់កម្ពុជា

| វិស័យនៃការគាំទ្រ | ២០០៥/០៦ | ២០០៦/០៧ | ២០០៧/០៨ | ២០០៨/០៩ |
|---|---|---|---|---|
| | មូលនិធិផ្តល់ជាក់ស្តែង ឆ្នាំ ២០០៥ (អឺរ៉ូ) | ប៉ាន់ប្រមាណអំពីការគ្រោងផ្តល់ (អឺរ៉ូ) | | |
| ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណនេយ្យភាព និងប្រសិទ្ធិភាពនៃការអភិវឌ្ឍ | ៣.២៥៦.០២៩ អឺរ៉ូ | ២.២៧៩.១៦៨ អឺរ៉ូ | ៤.៥៦៥.៧៦០ អឺរ៉ូ | ៤.៧១៤.២៤០ អឺរ៉ូ |
| អភិបាលកិច្ចនៅមូលដ្ឋាន | ៥.១៦៧.៦៣៥ អឺរ៉ូ | ៤.០០៨.៦៥៦ អឺរ៉ូ | ៤.៤៥៤.៤០០ អឺរ៉ូ | ៤.៤៥៤.៤០០ អឺរ៉ូ |
| ការចិញ្ចឹមជីវិត | ២២៨.០៥០ អឺរ៉ូ | ១.៦៣៣.២៨០ អឺរ៉ូ | ៣.២៦៦.៥៦០ អឺរ៉ូ | ៣.២៩៦.៣៥៦ អឺរ៉ូ |
| សេវាសុខភាព/សេវាជាមូលដ្ឋាន | ៣.១៥៥.៧៣៦ អឺរ៉ូ | ៤.១៤៤.២៧៣ អឺរ៉ូ | ៤.១៤៤.២៧៣ អឺរ៉ូ | ៥.៦៧១.១៨០ អឺរ៉ូ |
| មេរោគអេដស៍/ជម្ងឺអេដស៍ | ៦.២៧១.៦១៤ អឺរ៉ូ | ៦.៦៨៤.៩៤៧ អឺរ៉ូ | ៦.៣៣០.៩៨០ អឺរ៉ូ | ៦.៣៣០.៩៨០ អឺរ៉ូ |
| **សរុបជាអឺរ៉ូ** | **១៨.០៧៩.០៦៤** | **១៨.៧៥០.៣៦៤** | **២៣.១២០.១៨០** | **២២.២៧២.០៩៩** |
| **សរុបជាផោន** | **១២.១៧៦.០៩៥ ផោន** | **១២.៦៣៨.២០៨ ផោន** | **១៥.៧៤១.២៤៣ ផោន** | **១៥.០០០.០០០ ផោន** |

### ការិយាល័យបរទេស និងការិយាល័យតំណាងរដ្ឋធនរួម

ការិយាល័យបរទេស និងការិយាល័យតំណាងរដ្ឋធនរួម (FCO) បាននិងកំពុងផ្តល់ការគាំទ្រលើការងារជាច្រើនជំពូកនៅក្នុងប្រទេសកម្ពុជា និងដែលបានអនុវត្តដោយអង្គការមួយចំនួនជាដៃគូ រួមទាំងអង្គការអន្តរជាតិ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិផងដែរ។ មូលនិធិនេះបានទទួលការគ្រប់គ្រងដោយ ស្ថានទូតអង់គ្លេសនៅទីក្រុងភ្នំពេញ ដែលមានទឹកប្រាក់ចំនួន ៥៨០.០០០ អឺរ៉ូ នៅក្នុងឆ្នាំ ២០០៥/០៦។ សម្រាប់អំឡុងឆ្នាំ ២០០៦/០៧ មានការគ្រោងផ្តល់មូលនិធិចំនួន ៥៩៥.០០០ អឺរ៉ូ។



# ប្រទេសផ្សេងទៀត

## អូទ្រីស

សម្រាប់ជំនួយអភិវឌ្ឍន៍របស់ខ្លួន ប្រទេសអូទ្រីសបានអនុវត្តតាមគោលការណ៍ប្រមូលផ្តុំទៅតាមភូមិសាស្ត្រ និងប្រធានបទ។ ដោយសារកម្ពុជាមិនស្ថិតក្នុងចំណោមប្រទេសក្នុងកម្មវិធីជំនួយអភិវឌ្ឍន៍របស់ប្រទេសអូទ្រីស អូទ្រីសមានលទ្ធភាពតិចតួចប៉ុណ្ណោះក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ កាលានុវត្តភាព រួមមាន ការផ្តល់មូលនិធិជាអាហារូបករណ៍សម្រាប់ អ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវមួយចំនួនតូចផងដែរ។ ការគាំទ្រមួយផ្សេងទៀតត្រូវបានធ្វើឡើងនៅជុំវិញការផ្តល់មូលនិធិដល់គម្រោងរបស់ NGOs អូទ្រីស ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូនៅក្នុងមូលដ្ឋាន។

កាលពីអតីតកាល ប្រទេសអូទ្រីសបានរួមចំណែកក្នុងសកម្មភាពបោសសំអាតមីន ហើយឥឡូវនេះកំពុងផ្តល់ហិរញ្ញប្បទានដល់គម្រោងចំនួនពីរដែលអនុវត្តដោយអង្គការយូនីដូ: "អគ្គិសនីជនបទសម្រាប់ការប្រើប្រាស់ក្នុងផលិតកម្ម" (៧៦៧.០០០ អឺរ៉ូ) និង "ការគាំទ្រទីផ្សារសម្រាប់ប្រទេសកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពទាក់ទងនឹងវិទ្យាសាស្ត្រវាស់ភ្លើងក្រោមដី ការសាកល្បង និងការអនុវត្តតាម" (៤៨៧.០០០ អឺរ៉ូ)។

## លុចហ្សំបួរ

ការលុបបំបាត់ភាពក្រីក្រគឺជាគោលបំណងចំបងនៃកិច្ចសហប្រតិបត្តិការរបស់លុចហ្សំបួរ។ គោលបំណងនេះត្រូវបានអនុវត្តដោយផ្អែកលើគោលការណ៍អភិវឌ្ឍន៍ដោយចីរភាព ខាងផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន និងនៅក្នុងបរិបទនៃប្រធានបទដែលឆ្លុះបញ្ចាំងពីសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិរបស់លុចហ្សំបួរ ទាក់ទងនឹងការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ ដំណើរការលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។

កិច្ចសហប្រតិបត្តិការលុចហ្សំបួរក៏ផ្តោតការយកចិត្តទុកដាក់ផងដែរទៅលើការអភិវឌ្ឍសង្គមស៊ីវិល។ ជាក់ស្តែងរដ្ឋាភិបាលបានផ្តល់វិភាគទានហិរញ្ញវត្ថុបដិភាគដល់អង្គការមិនមែនរដ្ឋាភិបាលលុចហ្សំបួរចំនួនបី ដែលធ្វើការនៅក្នុងប្រទេសកម្ពុជា ខាងវិស័យសមាហរណកម្មសង្គមឡើងវិញ និងមីក្រូហិរញ្ញវត្ថុ។ ការផ្តល់ហិរញ្ញវត្ថុបដិភាគនេះមានប្រមាណ ១០៨.១៨៣ អឺរ៉ូ នៅឆ្នាំ ២០០៥ និង៣១២.៧៨០ អឺរ៉ូ នៅឆ្នាំ ២០០៦។

ក្រៅពីនេះ ធនាគារកណ្តាលនៃលុចហ្សំបួរ (BCL) បានរក្សាទំនាក់ទំនងជាមួយ "ធនាគារជាតិនៃកម្ពុជា" តាំងពីឆ្នាំ ២០០២ មកម៉្លេះ។ កិច្ចព្រមព្រៀងសហប្រតិបត្តិការផ្តល់ជំនួយទៅវិញទៅមករវាងធនាគារទាំងពីរបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៥។ នៅក្នុងក្របខ័ណ្ឌនេះ BCL បានផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិកម្ពុជា ជាពិសេសលើប្រព័ន្ធបង់ប្រាក់ក៏ដូចជាលើប្រព័ន្ធរដ្ឋបាលប្រាក់បម្រុងផងដែរ។ BCL ក៏បានផ្តល់ហិរញ្ញប្បទានផងដែរសម្រាប់មន្ត្រីក្របខ័ណ្ឌពីធនាគារជាតិកម្ពុជា ទៅសិក្សានៅសាលាហិរញ្ញវត្ថុលុចហ្សំបួរ។

ទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីលុចហ្សំបួរមកកម្ពុជា កាលពីថ្ងៃទី ២១ ដល់ ២២ ខែកញ្ញា ឆ្នាំ ២០០៦ បាននាំឱ្យមានការពង្រឹងចំណងទាក់ទងរវាងប្រទេសទាំងពីរ និងកត់សំគាល់សម្រាប់កិច្ចសហប្រតិបត្តិការរឹងមាំបន្ថែមទៀតទៅអនាគត។

# គណៈកម្មការសហគមន៍អឺរ៉ុប



## កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គណៈកម្មការសហគមន៍អឺរ៉ុប - កម្ពុជា

ឯកសារយុទ្ធសាស្ត្រប្រចាំប្រទេស (CSP) របស់គណៈកម្មការសហគមន៍អឺរ៉ុប និងកម្មវិធីចង្អុលបង្ហាញរបស់ជាតិ (NIP) កំណត់សកម្មភាពជំនួយរបស់ខ្លួនក្នុងប្រទេសកម្ពុជា ទន្ទឹមនឹងការតាមដាន និងគាំទ្រកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា។

ដូចមានគូសវាសនៅក្នុង CSP គោលដៅរួមនៃគោលបំណងសហប្រតិបត្តិការរបស់គណៈកម្មការសហគមន៍អឺរ៉ុប គឺផ្ដល់ការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងការធ្វើសមាហរណកម្មរបស់ប្រទេសនេះទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ក្នុងនាមជាដៃគូគន្លឹះមួយសម្រាប់ប្រទេសកម្ពុជា គណៈកម្មការសហគមន៍អឺរ៉ុប មានកម្មវិធីគាំទ្រលើវិស័យជាច្រើន ដូចជា សុខភាព និងការអប់រំ សន្តិសុខស្បៀង និងការអភិវឌ្ឍជនបទ វិមជ្ឈការ បរិស្ថាន ដំណើរការប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ក៏ដូចជាកំណែទម្រង់ពាណិជ្ជកម្មផងដែរ។

គម្រោង និងកម្មវិធីដែលទទួលមូលនិធិពីគណៈកម្មការសហគមន៍អឺរ៉ុប ត្រូវបានអនុវត្តដោយដៃគូអភិវឌ្ឍន៍នានា ដោយសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ និងតាមរយៈភាពជាដៃគូជាមួយទីភ្នាក់ងារពហុភាគី។ កិច្ចសហការជាមួយ NGOs អន្តរជាតិ និងក្នុងស្រុកបង្កើតជាផ្នែកសំខាន់មួយនៃសំណុំរឿងអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់គណៈកម្មការសហគមន៍អឺរ៉ុប។

បច្ចុប្បន្ននេះ គណៈកម្មការសហគមន៍អឺរ៉ុបផ្ដល់ការគាំទ្រដល់គម្រោងទ្វេភាគីមួយចំនួន ដែលមានទឹកប្រាក់ចំនួន ២៣.៤ លានអឺរ៉ូ ហើយផ្ដល់មូលនិធិដល់គម្រោងជាច្រើនដែលមានថវិកាបដិភាគរបស់ NGOs ដែលគិតជាទឹកប្រាក់មានចំនួន ៨.៦ លានអឺរ៉ូ និងគម្រោងមួយចំនួនទៀតនៅក្នុងក្របខ័ណ្ឌ កម្មវិធីសហប្រតិបត្តិការ EC-ASEAN និងគំរោងសំរាប់ទូទាំងទ្វីបអាស៊ី (Asia-wide Projects) ដែលនៅក្នុងនោះប្រទេសកម្ពុជាក៏បានចូលរួមផងដែរ។

| វិស័យ | មូលនិធិផ្ដល់ជាក់ស្ដែង ឆ្នាំ ២០០៥ | គ្រោងផ្ដល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្ដល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ការអប់រំ | ៥.៣៣១.២០៦ អឺរ៉ូ | ៥.៣៨៧.៣៥០ អឺរ៉ូ | ៦.៤២២.៣២០ អឺរ៉ូ |
| សុខភាព | ៣.៩០៨.២៣៧ អឺរ៉ូ | ៥.៤៥៥.០៧៧ អឺរ៉ូ | ៤.៥៣១.៩១៧ អឺរ៉ូ |
| សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ | | ១.៤៥០.៨៥៣ អឺរ៉ូ | ១.០១០.៥០៣ អឺរ៉ូ |
| សាលាក្ដីខ្មែរក្រហម | | ៩៩៥.១០០ អឺរ៉ូ | |
| អភិបាលកិច្ច និងសង្គមស៊ីវិល | ១.៧០៩.៦៦៧ អឺរ៉ូ | ២.៣៧៣.១៩៤ អឺរ៉ូ | ៤.១១៩.០០០ អឺរ៉ូ |
| ការអភិវឌ្ឍសង្គម | ៩០០.០០០ អឺរ៉ូ | ៦៨៥.៥៩៧ អឺរ៉ូ | ៦៨៧.៧៧២ អឺរ៉ូ |
| ការអភិវឌ្ឍជនបទ | ៩.០៩២.៩៥៤ អឺរ៉ូ | ២.៩៩៦.០៥៩ អឺរ៉ូ | ៧.០៤៩.១៧២ អឺរ៉ូ |
| កិច្ចការពារបរិស្ថាន | ១.៦០០.០០០ អឺរ៉ូ | ២.៩៩៨.៩២០ អឺរ៉ូ | ២.២៥២.៤២០ អឺរ៉ូ |
| ពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឯកជន | ២.៤០០.០០០ អឺរ៉ូ | ៣.៣៣១.០៣១ អឺរ៉ូ | ៤.៥៩០.២០០ អឺរ៉ូ |
| ជំនួយមនុស្សធម៌ (ECHO/DIPECHO – សូមអានទំព័របន្ទាប់) | ៤.៧៤១.៤៣៣ អឺរ៉ូ | ២.០០០.០០០ អឺរ៉ូ | ១.១០០.០០០ អឺរ៉ូ |
| កាត់បន្ថយអាវុធធុនតូច (គម្រោង EU ASAC) | ១.៣៧៥.៥៦៥ អឺរ៉ូ | ៦០០.០០០ អឺរ៉ូ | |
| **សរុប** | **៣១.០៥៩.០៦២ អឺរ៉ូ** | **២៨.២៧៣.១៨១ អឺរ៉ូ** | **៣១.៧៦៣.៣០៤ អឺរ៉ូ** |



# គណៈកម្មការសហគមន៍អឺរ៉ុប

## អគ្គនាយកដ្ឋានរបស់គណៈកម្មការសហគមន៍អឺរ៉ុប សម្រាប់ជំនួយមនុស្សធម៌ (ECHO)

ចាប់តាំងពីឆ្នាំ ១៩៩១ មក គណៈកម្មការសហគមន៍អឺរ៉ុបបានក្លាយជាម្ចាស់ជំនួយ និងជាដៃគូយ៉ាងសកម្ម ដែលធ្វើការឆ្ពោះទៅកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា។ ស្របគ្នានេះដែរ ដើម្បីកាត់បន្ថយជាបន្ទាន់នូវការឈឺចាប់របស់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារការប្រយុទ្ធគ្នា គ្រោះមហន្តរាយធម្មជាតិ ឬភាពក្រីក្រធ្ងន់ធ្ងរ គណៈកម្មការសហគមន៍អឺរ៉ុបបានផ្តល់មូលនិធិជិត ៦៨ លានអឺរ៉ូ តាមរយៈនាយកដ្ឋានជំនួយមនុស្សធម៌ (ECHO) របស់ខ្លួន ចាប់តាំងពីឆ្នាំ ១៩៩៣មក។ ដោយសារប្រទេសកម្ពុជាលែងប្រឈមនឹងភាពអាសន្ននៃតម្រូវការជំនួយមនុស្សធម៌ ហើយកម្មវិធីអភិវឌ្ឍន៍កំពុងកែលំអលក្ខខណ្ឌនៃការរស់នៅរបស់ជនក្រីក្រនៅទូទាំងប្រទេស គណៈកម្មការនេះនឹងលុបចោលជំនួយមនុស្សធម៌របស់ខ្លួននៅនិទាឃរដូវឆ្នាំ ២០០៧ ខាងមុខនេះ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មួយចំណែកធំនៃជំនួយមនុស្សធម៌របស់គណៈកម្មការសហគមន៍អឺរ៉ុបបានជួយក្នុងការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និងជនចំណាកស្រុកនៅក្នុងប្រទេស ដើម្បីស្តារការចិញ្ចឹមជីវិតរបស់ខ្លួនឡើងវិញ ក្រោយរយៈពេល ៣០ ឆ្នាំនៃជម្លោះ។ ឧទាហរណ៍ៈ គណៈកម្មការនេះ បានផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពបោសសំអាតមីន ការសង់អណ្តូងទឹក បង្គន់អនាម័យ និងបង្កើតសេវាសុខភាពជាមូលដ្ឋាននៅក្នុងតំបន់ដាច់ស្រយាល និងតំបន់រងគ្រោះដោយសារសង្គ្រាម។ ឱសថ និងសម្ភារៈជាមូលដ្ឋានសម្រាប់ការប្រើប្រាស់ប្រចាំគ្រួសារ និងផលិតផលអនាម័យក៏ត្រូវបានផ្តល់ឱ្យផងដែរ។

ចាប់តាំងពីឆ្នាំ ២០០០មក នៅពេលដែលស្ថានភាពមនុស្សធម៌មានស្ថិរភាពឡើងវិញនៅក្នុងខេត្តខ្លះៗ ECHO បានសម្រួលឱ្យមានការបញ្ចូលកម្មវិធីអភិវឌ្ឍន៍ និងចាប់ផ្តើមកាត់បន្ថយការផ្តល់មូលនិធិរបស់ខ្លួន។ គណៈកម្មការនេះបានបន្តផ្តល់ជំនួយមនុស្សធម៌នៅទូទាំងឆ្នាំ ២០០៦ នៅក្នុងតំបន់ដាច់ស្រយាលបំផុតក្នុងផ្ទៃប្រទេស ដែលពុំទាន់បានទទួល ឬ បានទទួលជំនួយអភិវឌ្ឍន៍តិចតួច។ ជំនួយមនុស្សធម៌ បានផ្តោតលើការជួយកាត់បន្ថយអត្រាមរណភាពទារក និងកុមារ និងការកែលំអលក្ខខណ្ឌនៃការរស់នៅរបស់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត។ មូលនិធិនេះត្រូវបានផ្តល់ ដើម្បីកែលំអសេវាថែទាំសុខភាព ដោយផ្តោតជាពិសេសលើទារក កុមារ ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅកូន ក៏ដូចជាសម្រាប់គម្រោងទឹកស្អាត និងអនាម័យផងដែរ។ នៅឆ្នាំ ២០០៥ និង ២០០៦ គម្រោងទាំងនេះបានផ្តល់សេវាសម្រាប់ប្រជាជនចំនួន ២ លាននាក់ ក្នុងនោះ ៧៥% មានអាយុក្រោម ១៥ ឆ្នាំ ។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់ និងភាពរាំងស្ងួតដែលបានកើតឡើងជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា គណៈកម្មការនេះបានផ្តល់ជំនួយបន្ថែមចំនួន ៣,៧ លានអឺរ៉ូ រវាងឆ្នាំ ១៩៩៨ និង ២០០៦ សម្រាប់សកម្មភាពត្រៀមបង្ការ និងការទប់ស្កាត់តាមរយៈកម្មវិធី DIPECHO របស់ខ្លួន។

ទោះបីត្រូវលុបចោលកម្មវិធីជំនួយមនុស្សធម៌របស់ខ្លួនក្តី គណៈកម្មការសហគមន៍អឺរ៉ុបនឹងនៅតែបន្តផ្តល់ការគាំទ្រដល់សកម្មភាពត្រៀមបង្ការ និងការតាមដានស្ថានភាពមនុស្សធម៌នៅក្នុងប្រទេសកម្ពុជាទៅទៀត ដើម្បីផ្តល់ជំនួយនៅពេលមានតម្រូវការចាំបាច់។

| ការរៀបចំតាមវិស័យ | មូលនិធិផ្ដល់ជាក់ស្ដែង ឆ្នាំ ២០០៥ | គ្រោងផ្ដល់ ឆ្នាំ ២០០៦ | ប៉ាន់ប្រមាណការផ្ដល់ ឆ្នាំ ២០០៧ |
|---|---|---|---|
| ជំនួយសង្គ្រោះបន្ទាន់ | ៣.៤៩៦ ៤៣៣ អឺរ៉ូ | ២.០០០.០០០ អឺរ៉ូ | ឥតគ្រោងទុក |
| ការត្រៀមបង្ការគ្រោះមហន្តរាយ (DIPECHO) | ១.២០៥.០០០ អឺរ៉ូ * | ៣៤១.០០០ អឺរ៉ូ | ១.១០០.០០០ អឺរ៉ូ * |
| **សរុប** | **៤.៧០១.៤៣៣ អឺរ៉ូ** | **២.៣៤១.០០០ អឺរ៉ូ** | **១.១០០.០០០ អឺរ៉ូ** |

** ការសម្រេចផ្ដល់មូលនិធិរបស់ DIPECHO បានធ្វើឡើងសម្រាប់កម្មវិធីដែលមានរយៈពេលពីរឆ្នាំម្ដង ពោលគឺ ឆ្នាំ ២០០៥-២០០៦ និង ២០០៧-២០០៨។ តួលេខសម្រាប់ឆ្នាំ ២០០៧ មានសុពលភាពសម្រាប់រយៈពេលពីរឆ្នាំ។*



# ព័ត៌មានសង្ខេបអំពីសហភាពអឺរ៉ុប

**ចាប់ខែមករា ឆ្នាំ២០០៧ ទៅ សហភាពអឺរ៉ុប នឹងមាន ២៧ ប្រទេសជាសមាជិក :** អូទ្រីស បែលហ្ស៊ិក ប៊ុលហ្គារី សាធារណរដ្ឋឆែក សាយប្រឹស ដាណឺម៉ាក់ អេស្តូនី អាល្លឺម៉ង់ ក្រិក ហ្វាំងឡង់ បារាំង អៀរឡង់ អ៊ីតាលី ហុងគ្រី ឡាទ្វី លីទុយអានី លុចហ្សំបួរ ម៉ាល់តា ហូឡង់ ប៉ូឡូញ ព័រទុយហ្គាល់ ស្លូវ៉ាគី ស្លូវេនៀ អេស្ប៉ាញ ស៊ុយអែដ រ៉ូម៉ានី និងចក្រភពអង់គ្លេស ។

- **មានប្រជាជនសរុបចំនួន ៤៨៥ លាននាក់**
- **ភាសាផ្លូវការចំនួន ២២ ភាសា**
- រូបិយប័ណ្ណតែមួយ - អឺរ៉ូ (€)នៅក្នុងរដ្ឋជាសមាជិកចំនួន ១៣ នៃសហភាពអឺរ៉ុប
- ៥៥% នៃជំនួយអភិវឌ្ឍន៍ផ្លូវការ បានមកពីសហភាពអឺរ៉ុប
- ៤០% នៃការនាំចូលរបស់សហភាពអឺរ៉ុប បានមកពីប្រទេសកំពុងអភិវឌ្ឍន៍

**រួបរួមគ្នាក្នុងភាពចម្រុះ:** សហភាពអឺរ៉ុប (EU) គឺជាគ្រួសារមួយនៃបណ្តាប្រទេសនៅអឺរ៉ុប ដែលមានការប្តេជ្ញាធ្វើការជាមួយគ្នាដើម្បីសន្តិភាព និងវិបុលភាព។ ចាប់ពីខែ មករា ឆ្នាំ ២០០៧ សហភាពអឺរ៉ុបនឹងគ្របដណ្តប់ប្រជាជាតិចំនួន ២៧ និងមានប្រជាជនសរុបចំនួន ៤៨៥ លាននាក់ ដែលធ្វើការដោះស្រាយបញ្ហាជាច្រើន ដែលមានសារៈសំខាន់ដោយផ្ទាល់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។

ដូចនៅអាស៊ីអាគ្នេយ៍ដែរ អឺរ៉ុបមានឫសគល់វប្បធម៌ចាស់ និងថ្មី។ អឺរ៉ុបគឺជាទ្វីបមួយដែលមានប្រពៃណី និងភាសាច្រើនខុសគ្នា ប៉ុន្តែក៏មានគុណតម្លៃរួមគ្នាផងដែរ ដូចជា ប្រជាធិបតេយ្យ សេរីភាព និងយុត្តិធម៌សង្គម ។ សហភាពអឺរ៉ុបការពារគុណតម្លៃទាំងនេះ និងលើកកំពស់គុណតម្លៃនេះនៅទូទាំងពិភពលោក ។

**ធ្វើពាណិជ្ជកម្មជាមួយគ្នា:** ដោយមានអ្នកប្រើប្រាស់ចំនួនប្រមាណ ៤៨៥ លាននាក់ សហភាពអឺរ៉ុបគឺជាទីផ្សារតែមួយដែលធំជាងគេលើពិភពលោក ។ ទីផ្សាររួមមួយបែបនេះអាចធានាថា ផលិតផលនាំចូល ធ្វើចលនាដោយសេរីនៅក្នុងសហភាពអឺរ៉ុប នៅក្រោយពេលដែលទំនិញទាំងនោះបានឆ្លងព្រំប្រទល់រួមខាងក្រៅរបស់សហភាពអឺរ៉ុបរួចហើយ ។ រូបិយប័ណ្ណឯកភាពគ្នាតែមួយគឺ "អឺរ៉ូ" ដែលធ្វើឱ្យរាល់ការធ្វើដំណើរ និងការធ្វើជំនួញកាន់តែងាយជាងពីមុន ។

សហភាពអឺរ៉ុបគឺជាទីផ្សារបើកចំហ ប៉ុន្តែទាមទារលក្ខខណ្ឌខ្ពស់ផងដែរ ។ អ្នកប្រើប្រាស់នៅអឺរ៉ុប ទាមទារគុណភាព ដោយសង្កត់ធ្ងន់លើកង្វល់ខាងសុខភាព និងបរិស្ថាន ។ ការនាំចេញរបស់ប្រទេសកម្ពុជា មានលទ្ធភាពលក់ទៅក្នុងទីផ្សារសហភាពអឺរ៉ុបដោយឥតគិតពន្ធ និងកូតាឡើយ ក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌ និងស្បែកជើងបានទទួលជោគជ័យបំផុត ។

**ធ្វើសកម្មភាពនៅទូទាំងពិភពលោក:** សហភាពអឺរ៉ុប គឺជាអ្នកដើរតួនៅទូទាំងពិភពលោក ដែលត្រៀមខ្លួនជាស្រេចក្នុងការចែករំលែកការទទួលខុសត្រូវដើម្បីកសាងពិភពលោកមួយប្រសើរជាងមុន ។ សហភាពអឺរ៉ុប ចូលរួមនៅក្នុងប្រតិបត្តិការថែរក្សាសន្តិភាព និងមានការប្តេជ្ញាដាច់ខាតក្នុងការប្រយុទ្ធប្រឆាំងអំពើភេរវកម្មនៅទូទាំងពិភពលោក ។ ប្រទេសណាមួយតែឯង មិនអាចដោះស្រាយការប្រឈមរបស់ពិភពលោកសព្វថ្ងៃនេះបានឡើយ ។ ដំណោះស្រាយពហុភាគី មានសារៈសំខាន់ណាស់ ដើម្បីដោះស្រាយការប្រឈម នៃសកលភាវូបនីយកម្ម ។ អឺរ៉ុបធ្វើការជាមួយដៃគូនានារបស់ខ្លួននៅជុំវិញពិភពលោក ដើម្បីលើកកំពស់ប្រជាធិបតេយ្យ សេរីភាព និង ស្ថិរភាព ដែលជាប្រព័ន្ធពាណិជ្ជកម្មពហុភាគីប្រកបដោយការបើកចំហ ។

**កសាងចំណងទាក់ទង:** សហភាពអឺរ៉ុបគឺជាម្ចាស់ជំនួយអភិវឌ្ឍន៍ធំជាងគេលើពិភពលោក ដែលជួយនាំមកនូវស្ថិរភាព និងវិបុលភាពដល់តំបន់ជាច្រើននៅលើពិភពលោក ។ សហភាពនេះក៏ប្រើប្រាស់ពាណិជ្ជកម្មផងដែរ ដើម្បីជម្រុញការអភិវឌ្ឍ ដោយបើកចំហទីផ្សាររបស់ខ្លួន សម្រាប់ការនាំចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចជាង ។

# ស្ថាប័នសំខាន់ៗនៃសហភាពអឺរ៉ុប



## សភាអឺរ៉ុប

http://www.europarl.europa.eu/

សភាអឺរ៉ុប ត្រូវបានបោះឆ្នោតជ្រើសរើសជារៀងរាល់ ៥ ឆ្នាំម្តង ដោយប្រជាពលរដ្ឋអឺរ៉ុប ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន។ ការងារចម្បងរបស់សភា គឺការអនុម័តច្បាប់អឺរ៉ុប និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលស្នើឡើងដោយសហភាពអឺរ៉ុប។ សភា និងក្រុមប្រឹក្សាសហភាពអឺរ៉ុបមានការទទួលខុសត្រូវរួមគ្នា សំរាប់ការផ្តល់នូវការអនុម័តយល់ព្រមទៅលើគម្រោងថវិកាប្រចាំឆ្នាំរបស់សភាអឺរ៉ុប ដែលមានចំនួន ១០០ ពាន់លានអឺរ៉ូ។

## ក្រុមប្រឹក្សានៃសហភាពអឺរ៉ុប

http://www.consilium.europa.eu/

ក្រុមប្រឹក្សាសហភាពអឺរ៉ុប ដែលកាលពីមុនត្រូវបានគេស្គាល់ថា ជាក្រុមប្រឹក្សារដ្ឋមន្ត្រី។ ក្រុមប្រឹក្សានេះរួមមាន រដ្ឋមន្ត្រីនានាមកពីរដ្ឋាភិបាលថ្នាក់ជាតិនៃប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបទាំងអស់ ដែលតែងតែជួបប្រជុំជាទៀងទាត់ ដើម្បីធ្វើការកំណត់ និងដោះស្រាយគោលនយោបាយនានារបស់អឺរ៉ុប។ ក្រុមប្រឹក្សាអឺរ៉ុបបង្កើតឡើងដោយប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកទាំង ២៥ ដែលតែងតែជួបប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ដើម្បីបង្កើតគោលដៅ និងកំណត់កិច្ចការជាចម្បង។ រដ្ឋជាសមាជិកនីមួយៗទទួលតំណែងជាប្រធានាធិបតេយ្យនៃសហភាពរៀងរាល់ ៦ ខែម្តង។

## គណៈកម្មការសហគមន៍អឺរ៉ុប

http://ec.europa.eu/

គណៈកម្មការសហគមន៍អឺរ៉ុប គឺជាស្ថាប័នប្រតិបត្តិនៃសហគមន៍អឺរ៉ុប មានសមាជិកចំនួន ២៥ រូប។ គណៈកម្មការអឺរ៉ុបទទួលខុសត្រូវក្នុងការធ្វើសេចក្តីព្រាងនៃសេចក្តីសំណើរផ្សេងៗ សំរាប់ច្បាប់ថ្មីៗរបស់សហភាពអឺរ៉ុប។ គណៈកម្មការអឺរ៉ុប គឺជាប្រធានគ្រប់គ្រង និងជាប្រធានប្រតិបត្តិនៃគោលនយោបាយរួមរបស់សហភាពអឺរ៉ុប និងនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ គណៈកម្មការនេះ ក៏ទទួលខុសត្រូវចំពោះការគ្រប់គ្រងជំនួយក្រៅប្រទេសរបស់សហភាពអឺរ៉ុបផងដែរ។

## តុលាការយុត្តិធម៌

http://curia.europa.eu/

ការងាររបស់តុលាការយុត្តិធម៌ គឺធ្វើឱ្យប្រាកដថា ច្បាប់របស់សហភាពអឺរ៉ុបត្រូវបានបកស្រាយ និងយកទៅអនុវត្តទៅតាមវិធីដូចគ្នា នៅក្នុងប្រទេសនៃសមាជិកសហភាពអឺរ៉ុបទាំងអស់។

## តុលាការសវនករ

http://www.eca.europa.eu/

តុលាការសវនករ ធ្វើការត្រួតពិនិត្យថា មូលនិធិរបស់សហភាពអឺរ៉ុបត្រូវបានចំណាយត្រឹមត្រូវតាមច្បាប់ថវិកា។

## ស្ថាប័នផ្សេងៗ

គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អឺរ៉ុប http://eesc.europa.eu/

គណៈកម្មការតំបន់ http://www.cor.europa.eu/

ធនាគារកណ្តាលរបស់អឺរ៉ុប http://www.ecb.int

ធនាគារវិនិយោគអឺរ៉ុប http://www.eib.org

## ប្រតិភូនៃគណៈកម្មការសហគមន៍អឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

http://www.delkhm.ec.europa.eu/

គណៈប្រតិភូនៃគណៈកម្មការអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា បានបើកដំណើរការនៅឆ្នាំ ២០០២។ ដូចគណៈប្រតិភូនៃគណៈកម្មការអឺរ៉ុបផ្សេងៗទៀតជុំវិញពិភពលោកដែរ វាជាបេសកកម្មការទូតមួយដែលតំណាងឱ្យប្រយោជន៍របស់អឺរ៉ុបក្នុងវិស័យជាច្រើន។ វាមិនមែនត្រួតគ្នានិងសកម្មភាពរបស់ស្ថានទូត នៃរដ្ឋសមាជិកសហភាពអឺរ៉ុបឡើយ ផ្ទុយទៅវិញវានាំមុខក្នុងវិស័យដែលត្រូវដោះស្រាយនៅកំរិតអឺរ៉ុប ជាជាងកំរិតជាតិ។

# European Union Representations

| | |
|---|---|
| **Embassy of Austria**<br>14 Soi Nandha, off Soi 1<br>Sathorn Tai Road<br>Bangkok 10121 - Thailand<br>Tel.: (66 2) 287 3970 / 303 6057-9<br>Fax: (66 2) 287 3925<br>bangkok-ob@bmaa.gv.at | **Embassy of Belgium**<br>Sathorn City Tower - 17th floor<br>175 South Sathorn Road<br>Tungmahamek - Bangkok 10120<br>Tel: +66(0)2-679.54.54<br>Fax: +66(0)2-679.54.65/67<br>Bangkok@diplobel.org |
| **Embassy of Czech Republic**<br>71/6 Ruam Rudee Soi 2, Ploenchit Road<br>Bangkok 10330 - Thailand<br>Tel.: (66 2) 255 3027 / 255 5060<br>Fax: (66 2) 253 7637<br>bangkok@embassy.mzv.cz<br>www.mfa.cz/bangkok | **Embassy of Denmark**<br>10, Soi 1, South Sathorn Road<br>Bangkok 10120 - Thailand<br>Tel.: (66 2) 343 1100<br>Fax: (66 2) 213 1752<br>bkkamb@um.dk<br>www.ambbangkok.um.dk |
| **Embassy of Finland**<br>16th Floor Amarin Tower, 500 Ploenchit Road, Lumpini, Pathumwan<br>Bangkok 10330 - Thailand<br>Tel.: (66 2) 256 9306 / 256 9309<br>Fax: (66 2) 256 9310<br>sanomat.ban@formin.fi | **Embassy of France**<br># 1, Monivong Blvd.<br>Phnom Penh - Cambodia<br>Tel.: (023) 430 020<br>Fax: (023) 430 038<br>ambafrance.phnom-penh-amba@diplomatie.gouv.fr |
| **Embassy of the Federal Republic of Germany**<br>#76-78 Yougoslavia Street (214)<br>Phnom Penh - Cambodia<br>Tel.: (023) 216 193 / 216 381<br>Fax: (023) 427 746<br>germanembassy@everyday.com.kh | **Embassy of Greece**<br>Unit No. 25/9-5, 9th Floor<br>BKI/YWCA Building, No. 25,<br>South Sathorn Road<br>Bangkok 10120, Thailand<br>Tel + 66 (0) 2679 1464-5<br>Fax +66 (0) 2679 1463<br>Email: bangkok@embgreece.or.th |
| **Embassy of Republic of Hungary**<br>Daeha Business Centre, 12 th Floor<br>360, Kim Ma Street<br>Hanoi - Vietnam<br>Tel.: (84 4) 771 5714 / 771 5715<br>Fax: (84 4) 771 5716<br>hungemb@hn.vnn.vn | **Embassy of Italy**<br>399 Nang Linchec Road, Thung Mahamek<br>Bangkok 10120 - Thailand<br>Tel.: (66 2) 285 4090 / 285 4093<br>Fax: (66 2) 285 4793<br>ambitbkk@loxinfo.co.th |
| **Embassy of Luxembourg**<br>Menara Keck Seng Building (16th Floor)<br>203 Jalan Bukit Bin Tang<br>55100 Kuala Lumpur - Malaysia<br>Tel.: (603)24 33 134<br>Fax: (603)24 33 157<br>kualalumpur.amb@mae.etat.lu | **Embassy of Netherlands**<br>#106 Wireless Road<br>Bangkok 10330 - Thailand<br>Tel.: (66 2) 254 7701 / 254 7705<br>Fax: (66 2) 254 5579<br>ban@minbuza.nl<br>www.netherlandsembassy.in.th/ |

# European Union Representations

| | |
|---|---|
| **Embassy of Poland**<br>767, Monivong Blvd.<br>Phnom Penh - Cambodia<br>Tel.: (023) 217 782/ 3<br>Fax: (023) 217  781<br>emb.pol.pp@online.com.kh<br>www.polishembassy-cambodia.org | **Embassy of Portugal**<br>#26 Bush Lane (Soi New Road 30) New Road<br>Bangkok 10500 - Thailand<br>Tel.: (66 2) 234 2123 / 234 0372<br>Fax: (66 2) 639 6113<br>portemb@loxinfo.co.th |
| **Embassy of Spain**<br>Lake Rajada Office Complex, 23rd Floor,<br>(Suite 98-99) 193, Ratchadapisek Road, Klongtoey<br>Bangkok 10330 - Thailand<br>Tel.: (66 2) 661 8284-6<br>Fax: (66 2) 661 9220<br>embespth@mail.mae.es<br>www.embesp.or.th | **Embassy of Sweden**<br>20th Floor, Pacific Place I 140 Sukhumvit Road<br>(Between Soi 4 & 6)<br>Bangkok 10110 - Thailand<br>Tel.: (66 2) 263 7200<br>Fax: (662) 263 7260<br>ambassaden.bangkok@foreign.ministry.se |
| **Embassy of the United Kingdom of Great Britain and Northern Ireland**<br>27-29, Street 75<br>Phnom Penh - Cambodia<br>Tel.: (023) 427 124 / 428 153<br>Fax: (023) 427 125<br>BRITEMB@online.com.kh | **Delegation of European Commission**<br>1, Street 21<br>Phnom Penh - Cambodia<br>Tel.: (023) 216 996 / 220 611<br>Fax: (023) 216 997<br>Delegation-Cambodia@ec.europa.eu<br>http://www.delkhm.ec.europa.eu/ |

| | |
|---|---|
| **The Office of Danish Development Cooperation Section (DANIDA)**<br>#8, Street 352, Boeung Keng Kang I<br>Phnom Penh - Cambodia<br>Tel.: (023) 987 629 / 211 484 / 993 075<br>Fax: (023) 993 065<br>danida@online.com.kh | **Department for International Development (DFID)**<br>#34, Monivong Blvd.<br>Phnom Penh - Cambodia<br>Tel.: (023) 430 240<br>Fax: (023) 430 254 |
| **European Commission Directorate General for Humanitarian Aid (ECHO)**<br>#9, Street 370<br>Phnom Penh - Cambodia<br>Tel.: (023) 224 082<br>Fax: (023) 212 576<br>echocambodia@online.com.kh | **Swedish International Development Co-operation Agency (Sida)**<br>Section for Development Co-operation<br>#8, Street 352, Boeung Keng Kang I<br>Phnom Penh - Cambodia<br>Tel.: (023) 212 259<br>Fax: (023) 212 867<br>sida@online.com.kh |




Printed with the support of the European Union



Delegation of European Commission to Cambodia
#1, Street 21, Tonle Bassac, Chamkarmon
Phnom Penh, P.O. Box 2301
Tel: 855-23 220 611/2   Fax: 855-23 216 997
E-mail: Delegation-Cambodia@ec.europa.eu
Website: www.delkhm.ec.europa.eu



Designed by Graphic Roots: www.graphicroots.com.kh